សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal Univercity of Law and Economics

# ប្រវត្តិគំនិតនយោបាយ



## ខុង ជឺ

សាស្ត្រាចារ្យ : អ៊ុន សក្កដា

រៀបរៀងដោយនិស្សិតក្រុម : L2B2

- ក. ស សំណាងវឌ្ឍនា
- ក. ប៉ា សុគន្ធារី
- ក. ញឹក សំបូរ
- ក. មាច សុភារី

2008-2009

This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

# មាតិកា

ទំព័រ


**សេចក្តីផ្តើម....................................................** ១

**១. ជីវប្រវត្តិ..............................................** ២

**២. ប្រវត្តិស្នាដៃ..............................................** ៣

ក. អំពីសៀវភៅក្លាស៊ិក .......................................................... ៣

ខ. ការធ្វើអោយត្រឹមត្រូវតាមឈ្មោះ .......................................... ៤

គ. មនសិការភ្ញាក់រលឹក........................................................ ៥

ឃ. ការយល់ដឹងអំពីវាសនា.................................................... ៥

**៣. អំពីសាវ័កខុងជឺ.............................................** ៦

**៤. ទស្សនៈនយោបាយរបស់ខុងជឺ...................................** ៧

ក. គោលការណ៏អប់រំ .......................................................... ៧

ខ. អហឹង្សានៃទស្សនៈវិជ្ជារបស់ ខុង ជឺ........................................ ៩

គ. អត្ថន័យនៃទស្សនៈវិជ្ជារបស់ ខុង ជឺ........................................ ៩

ឃ. គោលការណ៏គុណធមិរបស់ ខុង ជឺ........................................ ១០

**៥.ទស្សនៈនយោបាយគ្រប់គ្រងរដ្ឋ និងជំបូន្មានរបស់ខុងជឺ................** ១០

**៦.ខុងជឺ និង ទំនៀមទម្លាប់ចិន.........................................** ១១

**៧.ទស្សនវិជ្ជាខុងជឺរំលាយមហាកំពែងចិន...............................** ១២

**៨.អវសាននៃជីវិត ខុង ជឺ................................................** ១៧

**សេចក្តីសន្និដ្ឋាន........................................................** ២០

**ឯកសារយោង..........................................................** ២១



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

# មាតិកា

ទំព័រ.


~ សេចក្តីផ្តើម ................................................ ១.

១. ជីវប្រវត្តិ ................................................ ២.

២. ប្រវត្តិស្នាដៃ ................................................ ៣.

ក. អំពីសៀវភៅក្លាស៊ិក ................................................ ៣.

ខ. ការធ្វើអោយត្រឹមត្រូវតាមឈ្មោះ ................................................ ៤.

គ. ចនសិការភ្ញាក់រលឹក ................................................ ៥.

ឃ. ការយល់ដឹងអំពីវាសនា ................................................ ៥.

៣. អំពីសាវ័ក ខុង ជឺ ................................................ ៦.

៤. ទស្សនៈនយោបាយរបស់ ខុង ជឺ ................................................ ៧.

ក. គោលការណ៍អប់រំ ................................................ ៧.

ខ. អហឹង្សានៃទស្សនវិជ្ជា ខុង ជឺ ................................................ ៩.

គ. អត្ថន័យនៃទស្សនវិជ្ជា ខុង ជឺ ................................................ ៩.

ឃ. គោលការណ៍គុណធម៌របស់ ខុង ជឺ ................................................ ១០.

៥. ទស្សនៈនយោបាយគ្រប់គ្រងរដ្ឋ និងដំបូន្មានរបស់ខុង ជឺ ................................................ ១០.

៦. ខុង ជឺ និង ទំនៀមទម្លាប់ចិន ................................................ ១១.

៧. ទស្សនវិជ្ជាខុង ជឺ រំលាយមហាកំពែងចិន ................................................ ១២.

៨. អវសាននៃជីវិត ខុង ជឺ ................................................ ១៧.

~ សេចក្តីសន្និដ្ឋាន ................................................ ២០.

~ ឯកសារយោង ................................................ ២១.



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

# សេចក្តីផ្តើម

**ខុង ជឺ** គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សមួយចំនួនតូច ដែលមានឥទ្ធិពលទៅលើប្រវត្តិសាស្ត្រមនុស្សជាតិ ដោយសារតែកំលាំងផ្ទាល់ខ្លួន ដោយសារអំណោយទាន និងស្នាដៃខាងបញ្ញា។ "ខុង ជឺ" ជាឈ្មោះសរសេរតាមអក្សរឡាតាំង **KUNG CHIU** ។ ចំណែកពួកបស្ចឹមប្រទេសហៅ **ខុង ជឺ** ថា " **កុងហ្វូ ស៊ីយូស** " **CONFUCIUS** ។ ប៉ុន្តែនៅប្រទេសចិនវិញ គេហៅថា "**គង់ ស៊ូ**" ។ តាមពិតទស្សនវិទូរូបនេះឈ្មោះ"**ជឺ**" ត្រកូល "**ខុង**" ។ លោកជាមហាទស្សនៈវិទូចិនបុរាណសម័យមួយរូបដ៏ល្បីល្បាញ មានកិត្តិយសស្មើនឹងសូក្រាតប្រទេសក្រិច ។ ប្រការដែល **ខុង ជឺ** លេចធ្លោឡើងបែបនេះ គេមិនអាចបកស្រាយបានទាំងស្រុងនោះទេ ។ ប៉ុន្តែតាមរយៈ ការពិនិត្យពីកាលៈទេសៈរស់នៅរបស់គាត់ យ៉ាងហោចណាស់ ក៏យើងអាចបង្កើនសមត្ថភាពរបស់យើង ដើម្បីយល់ពីគាត់បានខ្លះដែរ។ ការប៉ុនប៉ងរបស់យើងដើម្បីយល់ពី ខុង ជឺ ត្រូវជួបការលំបាកដោយសារតែរឿងព្រេង និងប្រពៃណីជាច្រើនដែលប្រមូលផ្តុំទៅលើឈ្មោះគាត់អស់ច្រើនសតវត្សធ្វើអោយពិបាកជឿថាជាការពិត។ ការសិក្សាស្រាវជ្រាវនេះ ធ្វើមិនអោយខុសភាពដើមទេគឺគ្រាន់តែជាការខិតខំប្រមែប្រមូលចងក្រងឯកសារដោយចាត់ទុកជា ប្រភពពត៌មានសំរាប់ការសិក្សាតែប៉ុណ្ណោះ។ ដូចនេះ មាគ៌ាតែមួយគត់របស់យើង គឺមិនយកចិត្តទុកដាក់ហួសហេតុដល់រឿងរៀបរាប់បែបអច្ឆរិយៈពីជីវភាព និងគំនិតរបស់គាត់ដោយផ្អែកតែលើភស្តុតាងបន្តិចបន្តួចដែលគេប្រមូលបានថាជាការពិតនូវអ្វីដែលគាត់បានធ្វើ។ បញ្ហាសំខាន់ដែលយើងចង់បាន គឺទស្សនវិទូរូបនេះ បានដោះស្រាយ និងបង្កើតទ្រឹស្តីទស្សនវិជ្ជាបែបណាមកអប់រំប្រជាជនចិន? នៅប្រទេសចិនគេចាត់ទុកទស្សនវិទូជាច្រើនប្រភេទ ។ អ្នកដែលចូលចិត្តសិក្សាទស្សនវិជ្ជានយោបាយ គឺច្រើនតែជាអ្នកដឹកនាំរដ្ឋដែលប្រកបដោយកិត្តិនាមល្បីល្បាញ។

ដើម្បីពង្រីកឆន្ទៈនៃបុគ្គលម្នាក់ៗអោយស្មើនឹងអកុសលកម្មដែលរុំពទ្ធ័ជីវិតនោះ ទស្សនវិជ្ជាបានដាក់បញ្ហាអោយដោះស្រាយថា តើសត្វលោកទាំងអស់ដែលបានផុងខ្លួនចាញ់បោកជីវិតហើយនោះ ត្រូវរកមធ្យោបាយយ៉ាងណាដើម្បីរំដោះខ្លួនពីគុកនៃជីវិតនេះ? តើគេម្នាក់ៗត្រូវលះបង់សង្គមទាំងស្រុង ឬក៏ត្រូវខំពទ្ធ័ចិត្តអោយចេះស្អប់ខ្ពើមជីវិតខ្លួន? មានទស្សនវិទូជាច្រើននៅក្នុងលោកសុខចិត្តលះបង់ចោលសង្គមមនុស្ស ហើយជួនកាលគេសុខចិត្តលះបង់ជីវិតរបស់គេទៀតផង ។ នេះជាមាគ៌ាមួយដែលទស្សនវិទូជាច្រើនបាន ជ្រើសរើសមកអនុវត្តសំរាប់ រំដោះខ្លួនអោយរួចផុតពីជីវិត ។ ចុះចំណែកខុងជឺវិញ តើទស្សនៈរបស់គាត់ជាទស្សនវិជ្ជាបែបណា?



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

## ១. ជីវប្រវត្តិ

**ខុង ជឺ** ត្រូវបានពួកអ្នកនិពន្ធបច្ចិមប្រទេសហៅថា "កុងហ្វូស៊ីយូស " ជាមហាទស្សនវិទូចិនមួយរូបដ៏ល្បីល្បាញ កើតនៅឆ្នាំ ៥៥១ មុន គ.ស ក្នុងកុលសម្ព័ន្ធ លូស្ថិតនៅខាងត្បូងខេត្តចាន តុង នៃ អាណាចក្រចិន ខាងកើត ។ ត្រកូលរបស់លោកជារាជវង្សអភិជនដែលមានពូជតមកពីរាជវង្ស " **ចាង** " ដែលជាសន្តតិវង្ស មួយគ្រប់គ្រងប្រទេសចិនមុនសម័យរជ្ជកាល **ចូវ** តែដោយសារសង្គ្រាមវាយលុកពី កុលសម្ព័ន្ធ " ចូវ " ស្ថិតនៅពាយ័ព្យនៃទន្លេលឿង ហើយរាជវង្សចាងក៏រលាយបាត់បង់ក្នុងសង្គ្រាម ។ ឯសមាជិកគ្រួសារដែលរួចពីស្លាប់ក៏ បន្លំខ្លួនក្នុងកុលសម្ព័ន្ធ " **លូ** " ។

មុនពេលចាប់កំនើតម្តាយគាត់បានសុបិន្តឃើញថា មាននាគមួយសម្បុរខៀវ ហោះពីលើអាកាស ទម្លុះដុំពពករួចចុះមកលេងទឹក ក្រោយហែលចុះឡើងៗ នាគខៀវផឹកទឹកពេញពោះរួចទើបហោះ ទៅលើមេឃវិញ ។ ពេលនោះនាគបានខ្ជាក់ទឹកភ្លៀងមកលើដី កើតទៅជាភោគផលចំរើនផលកសិកម្ម ដើមស្រូវដុះគុម្ពធំៗ ក្រោយមកម្តាយគាត់ក៏មានផ្ទៃពោះ ហើយសំរាលបានបុត្រមួយគឺ ខុងជឺ តែថ្ងៃកំនើតរបស់ខុងជឺមានអព្ភូតហេតុចំលែកកើតឡើងគឺ ព្យុះភ្លៀង រន្ទះ រញ្ជួយដី ផ្ទុះភ្នំភ្លើង ធ្វើឱ្យគេយល់ថាខុងជឺគឺជាមនុស្សមានបុណ្យមកចាប់កំនើត ។ ក្រោយមកគ្រួសាររបស់ខុងជឺបានផ្លាស់ទីលំនៅ មកក្នុងទីប្រជុំជនមួយកន្លែងក្បែរភូមិគ្រឹះនៃអភិជនម្នាក់ក្នុងសន្តតិវង្សលូ ស្រុកចានតុងដដែល ។ ឪពុករបស់ខុងជឺ គឺជាមេទ័ពដែលមានជីវភាពខ្វះខាតជានិច្ច ។ តែគាត់ជាមនុស្សដែលមានសន្តានចិត្តសប្បុរសធម៌ តាំងពីក្មេងវ័យទោះជាគាត់រស់ក្នុងជីវភាពទីទាល់ក្រក្តី ។ ប៉ុន្តែគាត់បានធ្វើមរណៈកាល នៅពេលដែលខុងជឺបានចំរើនវ័យ ៣ ឆ្នាំ ។ ឯម្តាយខុងជឺ គឺជាស្ត្រីគ្រប់លក្ខណ៍ ប្រកបដោយសតិញ្ញាឆ្លាតវាងវៃ និង ជាអ្នកព្យាបាលជំងឺដ៏ពូកែសក្តិសិទ្ធិម្នាក់ផងដែរ ។ នៅអាយុ១២ឆ្នាំ ខុងជឺ គឺជាក្មេងគង្វាលម្នាក់ ហើយបានជួយសង្គ្រោះមិត្តភក្តិគាត់ជាច្រើនដែលជួបប្រទះនឹងមហន្តរាយផ្សេងៗ ហើយគាត់ជាក្មេង ដែលគោរពម្តាយគេណាស់ ។ អ្វីដែលម្តាយគេហាមមិនឱ្យធ្វើនោះគេពុំហ៊ានធ្វើឡើយ ទោះបីមានគេបង្ខំវាយ ដំឬចង់ សម្លាប់ក៏ដោយ ។ គាត់នៅតែខំអត់សង្កត់ចិត្តរក្សា ឧត្តមគតិកតញ្ញូតាធម៌ចំពោះម្តាយជានិច្ច ។ មានន័យថាគាត់ហ៊ានបូជាជីវិតខ្លួនដើម្បីម្តាយខ្លួន ។ នេះសរបង្ហាញពីចរិយាសាស្ត្រដែលជាគុណធម៌ក្នុងលោក ដែលគាត់ឱ្យតម្លៃជាពិសេសទៅលើ "គុណ" ។

ខុងជឺបានរៀបការជាមួយស្រីជនជាតិម៉ុងហ្គោល ម្នាក់ដែលត្រូវពួកមេដឹកនាំឈ្លានពានសំពៅយកមក លក់ឱ្យពួកត្រកូលអភិជនធ្វើជាទាសី ។ តែនាងមានល្បិច ធ្វើជាលេបថ្នាំបំផ្លាញសម្ផស្ស ដែលអាចធ្វើឱ្យនាងរួចផុតពីការចាប់យកទៅធ្វើជាទាសីបាន និង បានរត់ទៅស្រុកព្យាបាលរហូត បានជាសះស្បើយពីជំងឺ រួចត្រលប់មករៀបការនឹងខុង ជឺវិញ ។ គាត់បានប្រសូត្របុត្រម្នាក់ឈ្មោះ លី ។ នាសម័យ នោះ ខុងជឺ គឺជាគ្រូបង្រៀនដ៏ល្បីល្បាញម្នាក់ ក្រៅពីនេះគាត់គឺជាអាចារ្យសាសនាដែលទទួលការ គោរពជាច្រើនពីប្រជារាស្ត្រ ។ គាត់បានបណ្តុះគំនិតឱ្យពួកគេចេះ គោរពសែនព្រេនជូនតាតាមលក្ខណៈ បែបផែនថ្មី ។ នៅក្នុងស្រុក ចាន តុង គាត់មានឈ្មោះបោះសំលេងនូវទស្សនៈវិជ្ជារបស់គាត់ដែលមានអត្ថន័យបង្រៀនមនុស្សឱ្យប្រព្រឹត្តតាមអ្វី ដែលសមស្រប និង ប្រកបដោយគុណធម៌ ។ គាត់ត្រូវបានតែងតាំង



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

ជាសេនាធិបតី មានឋានៈដ៏ធំម្នាក់នៅក្នុងវាំង ក្នុងអាយុ ៤៩ ឆ្នាំ។ ហើយ គាត់ បានផ្សព្វផ្សាយទស្សនៈវិជ្ជារបស់គាត់គ្រប់ទិសទីពាសពេញប្រទេសចិន ដើម្បីចង់ឱ្យពលរដ្ឋទាំងអស់យល់ដឹង នូវតំលៃរបស់ខ្លួន និង កែប្រែរបៀបនៃការអប់រំសីលធម៌ តែត្រូវព្រះមហាក្សត្រជំទាស់។ ក្រោយមក មានវិបត្តិនយោបាយទើបភៀសខ្លួនចេញពីស្រុកអស់រយៈពេល ២៣ ឆ្នាំទើបអាចត្រលប់មកស្រុកវិញ នៅពេលវ័យកាន់តែចាស់ ៧០ឆ្នាំ និង បានបង្រៀនទស្សនៈវិជ្ជារបស់គាត ដល់សិស្សអស់រយៈពេលជាង ១៣ ឆ្នាំ ។ គាត់បានអប់រំកែប្រែឱ្យប្រជាជនចិនបោះបង់នូវទំលាប់ចាស់គំរិល ដែលគ្មានគុណធម៌ចោល ដូចជាការសំលាប់ទាសាទាសី សេនាទ័ព អាមាត្យ សេះ ក្នុងរណ្តៅរួមរបស់ព្រះមហាក្សត្រដែលសោយទីវង្គត ដើម្បីឱ្យស្លាប់ទៅតាមបំរើព្រះអង្គតទៅទៀត។ ដោយគាត់បានណែនាំឱ្យគ្រួសារសពបង្ហាញទុក្ខសោក ដឹងគុណ និង ទំលាប់សែនផ្លូវដូនតារាល់ឆ្នាំ ជាជាងការសំលាប់មនុស្សដើម្បីកំដរព្រលឹងខ្មោច។ ហើយចាប់តាំងពីសម័យគាត់ ប្រជាជនបានប្រើជក់ថ្នាំដុសខ្មៅសរសេរលើក្រដាស ។ គាត់បានចងក្រងនូវគម្ពីរ " **លាវ យី** " ដែលជាគម្ពីរអប់រំខាងសិល្បៈសេរី មានគោលដៅស្វែងរកនូវសេរីភាព ក្នុងនយោបាយ និង សេដ្ឋកិច្ច។ ខុងជឺ បានទទួលមរណៈភាពក្នុងឆ្នាំ ៤៧៩ មុនគ.ស ក្នុងជន្មាយុ ៧២ ឆ្នាំ។

## ២. ប្រវត្តិស្នាដៃ

### ក. អំពីសៀវភៅក្លាស៊ិក

ទស្សនវិជ្ជា ខុង ជឺ ដែលគេស្គាល់ថាជា " **ក្បួនសិក្សាទស្សនវិជ្ជាទាំង៦** " នោះត្រូវបានគេយកមកពិចារណាពុំចេះចប់ពុំចេះហើយសោះ។

អ្នកខ្លះពោលថា **ខុង ជឺ** ពុំមែនជាអ្នកនិពន្ធនូវក្បួនខ្នាត ឬជាអ្នកបង្កើតនូវក្បួនទស្សនវិជ្ជា ឬច្បាប់អនុវត្តពិធីផ្សេងៗទាំងនោះទេ គាត់គ្រាន់តែជាអ្នករក្សានូវក្បួនទូន្មានវប្បធម៌ទំនៀមទំលាប់របស់បុព្វបុរសសម័យចាំងប៉ុណ្ណោះឯង ។

**ហ្វុង យូឡាន** បានឱ្យយោបល់ថា ការពោលបែបនេះពុំសមហេតុផលសោះ ហើយយើងក៏ពុំបានចាត់ទុកថាជាសំដីមានខ្លឹមសារអ្វីឡើយ។ ថ្វីបើមុនសម័យ **ខុង ជឺ** ចិនមានក្បួនខ្នាតនានាសំរាប់ការកសាងសង្គម ទំនៀមទំលាប់ជំនឿ សាសនារបស់ខ្លួនហើយក៏ដោយ ក៏ចិនពុំទាន់មានគម្ពីរទស្សនវិជ្ជាត្រឹមត្រូវសំរាប់ការអនុវត្តន៍នៃប្រជាជនក្នុងនគរគ្រប់គ្នាទេ។

**ខុង ជឺ** បានសរសេរទស្សនវិជ្ជារបស់លោកដោយផ្អែកលើទំនៀមទំលាប់ខ្លះៗនោះ ក៏ក្នុងគោលបំណងប្រមូលវិធី សាស្រ្តអប់រំជំនាន់ដើមមកបូកបញ្ចូលជាមួយទំនៀមទំលាប់ស្រុកចិន រួចហើយក៏ចងក្រងជាទស្សនវិជ្ជាថ្មីមួយ ដែលយើងឃើញនៅក្នុងសៀវភៅ ៦ក្បាល មានទុករហូតមកដល់សព្វថ្ងៃនេះ។

អ្នកប្រាជ្ញឈ្មោះ **លាវ ហ៊ីន** បានសរសេរថា " ខុង ជឺ ឱ្យឈ្មោះសៀវភៅទាំង៦ ក្បាលនោះថា **លាវ យី** ដែលមានគោលបំណងចង់បង្ហាញដល់មនុស្សនូវយុត្តិធម៌ និង មនុស្សធម៌"។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

ពាក្យ លាវ យី ប្រែថា " **សិល្បៈទាំង ៦**" ជាសិល្បៈសេរីភាពគោលដៅស្វែងរកនូវសេរីភាពឯកត្តជនក្នុងនយោបាយ និងសេដ្ឋកិច្ច ។

ទស្សនៈវិជ្ជាទាំង៦ របស់ **ខុង ជឺ** គឺ :

-ទី ១ : សៀវភៅស្តីអំពីការផ្លាស់ប្តូរ ( Book of change )មានឈ្មោះថា"**យី**"។ សៀវភៅនេះចែងអំពីការផ្ទេរកម្មសិទ្ធិមរតិក ជាគម្ពីរច្បាប់របស់ប្រទេសចិននិយាយអំពីអំណាចមេគ្រួសារ ឬអំណាចរបស់ប្រទេសដែលត្រូវផ្ទេរទៅឱ្យកូនក្នុងត្រកូលនីមួយៗ ។

-ទី ២ : សៀវភៅកំណាព្យមានឈ្មោះថា "**ចេ**"។ ក្នុងសៀវភៅនេះមានសុទ្ធតែកំណាព្យនិពន្ធចងក្រងឡើងសំរាប់បំរើសោភ័ណក្នុងធម្មជាតិ ទុកចងដៃដល់កវីនិពន្ធជំនាន់ក្រោយ ។

-ទី ៣ : សៀវភៅស្តីអំពីទំនៀមទំលាប់មានឈ្មោះថា "**លី**"។ ក្នុងសៀវភៅនេះមានចែងអំពីការគោរពធ្វើពិធីបន់ស្រន់សែនព្រេនផ្សេងៗមានលក្ខណៈដូចជា គម្ពីឧប្បនិស្សាត (UPANISAD) នៅប្រទេសឥណ្ឌាដែរ តែខុសត្រង់ថា ឧប្បនិស្សាតមានលក្ខណៈកល្បៈ ( KALPA )ជាងគម្ពី លី របស់**ខុង ជឺ**។

-ទី ៤ : សៀវភៅស្តីអំពីចំរៀងមានឈ្មោះថា " **យ៉ូ**"។ សៀវភៅនេះសរសេរពីបទភ្លេង និង ចំរៀងបណ្តែតអារម្មណ៏ ច្រៀងរៀបរាប់អំពីសត្វលោកដែលកំព្រានៅក្នុងធម្មជាតិដោយមានយកភ្នំ ទន្លេ សមុទ្រ ពពក ខ្យល់ជាគ្រឿងឧប្បមាណរូបារម្មណ៏ ។

-ទី ៥ : សៀវភៅអំពីប្រវត្តិសាស្រ្តមានឈ្មោះថា ( Shu ) ចែងពីពង្សាវតាប្រទេសចិន ។

-ទី ៦ : សៀវភៅ "និទាឃរដូវ" ( Spring and Autumn )សៀវភៅនេះជាអត្ថបទប្រវត្តិសាស្រ្តជាក់ស្តែងក្នុងសង្គម សន្តិវង្សលូ ដែលខុង ជឺ បាននិពន្ធឡើងនៅពេលលោកជិតចូលមរណៈភាព គឺរវាងឆ្នាំ ៤៧៩ មុនគ.ស ។

## ខ. ការធ្វើអោយត្រឹមត្រូវតាមឈ្មោះ

ក្រៅពីការបកស្រាយថ្មីដែល **ខុង ជឺ** បានផ្តល់ដល់សៀវភៅក្លាសិក គាត់ក៏មានគំនិតផ្ទាល់ខ្លួនអំពីបុគ្គលនិងសង្គម អំពីអាទិទេព និងមនុស្ស ។

ចំពោះសង្គមគាត់ចាត់ទុកថា ដើម្បីអោយសង្គមមានសណ្តាប់ធ្នាប់ល្អ បញ្ហាសំខាន់បំផុតគឺអនុវត្តនូវអ្វីដែលគាត់ហៅថា ការកែតំរូវអោយស្របតាមឈ្មោះ ។ ពោលគឺវត្ថុទាំងឡាយនៅក្នុងហេតុការណ៏ពិតគេគួរតែធ្វើអោយស្របនឹងភាពស្មុគស្មាញដែលផ្សារភ្ជាប់ និង វត្ថុនោះដោយឈ្មោះទាំងឡាយ ។ នៅពេលសាវ័កម្នាក់សួរគាត់ តើត្រូវធ្វើអ្វីមុនគេ ប្រសិនបើគាត់ជាអ្នកគ្រប់គ្រងរដ្ឋ? ខណៈនោះ **ខុង ជឺ** ឆ្លើយថា " បញ្ហាដែលចាំបាច់មុនគេបំផុតគឺ ការកែតំរូវអោយស្របតាម ឈ្មោះ" ។

នៅពេលដែលសាវ័កម្នាក់ក្នុងសម័យនោះសួរ**ខុង ជឺ** ពីគោលការណ៏ត្រឹមត្រូវរបស់រដ្ឋាភិបាល ចំពោះសំណួរនេះគាត់ឆ្លើយថា " អ្នកគ្រប់គ្រងគឺអ្នកគ្រប់គ្រង រដ្ឋមន្រ្តីគឺរដ្ឋមន្រ្តី ឪពុកគឺឪពុក ហើយកូនគឺកូន "។ និយាយម៉្យាងទៀតគ្រប់ឈ្មោះមានភាពស្មុគស្មាញមួយចំនួនដែលបង្កើតជាថ្នាក់នៃ វត្ថុទាំងឡាយដែលត្រូវបានអនុវត្ត។ ដោយមូលហេតុ



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

នោះ វត្ថុបែបនេះគួរតែស្របនឹងខ្លឹមសារឧត្តមគតិ ។ ខ្លឹមសាររបស់អ្នកគ្រប់គ្រង គឺត្រូវតែមានឧត្តមគតិ ឬអ្វីដែលនៅប្រទេសគេហៅថា "វិធីរបស់អ្នកគ្រប់គ្រង" ។ ប្រសិនបើអ្នកគ្រប់គ្រងម្នាក់ធ្វើអំពើយោង តាមវិធីរបស់អ្នកដឹកនាំគ្រប់គ្រងនោះ គេពិតជាអ្នកគ្រប់គ្រងដ៏ល្អពោលគឺមានការស្របគ្នារវាងឈ្មោះ និងការពិត។ ប៉ុន្តែប្រសិនបើគេមិនអនុវត្តអោយមានការស្របគ្នារវាងឈ្មោះ និងការពិតនោះ គឺគេប្រាកដជាមិនមែនជាអ្នកគ្រប់គ្រង ទោះបីមានប្រជាប្រិយភាពយ៉ាងណាក៏ដោយ ។

ឈ្មោះទាំងអស់នៅក្នុងទំនាក់ទំនងសង្គម បញ្ជាក់អំពីទំនួលខុសត្រូវ និង ភារកិច្ច។ រដ្ឋមន្ត្រី ឪពុក និងកូន គឺជាឈ្មោះនៃទំនាក់ទំនងនៅក្នុងសង្គម ។ បុគ្គលទាំងឡាយដែលមានឈ្មោះបែបនេះទាំងអស់ត្រូវតែមានទំនួលខុសត្រូវ និង មានភារកិច្ចរបស់ខ្លួនអោយបានសមស្រប ។

នេះជាភាពស្មុគស្មាញក្នុងទ្រឹស្តីរបស់ **ខុង ជឺ** អំពីការតំរូវអោយស្របតាមឈ្មោះ ។

## គ. មនសិការភ្ញាក់រលឹក

**ជុង** ប្រែថា ត្រូវទុកចិត្តខ្លួនឯង និងហាត់ទុកចិត្តលើអ្នកដទៃ។ **ស៊ីង សាន** សាវ័កមហាញាណទី១របស់ខុង ជឺ បាន បញ្ជាក់ថា " បុគ្គលច្រើនណាស់ដែលគ្មានសចក្តីក្លាហានទុកចិត្តលើខ្លួនឯង ហើយមានបុគ្គលច្រើនដែលចូលចិត្តទុកចិត្តលើអ្នកដទៃ ។ បើពុំទាន់ទុកចិត្តខ្លួនឯងទេចូរកុំអាលទុកចិត្តលើអ្នកដទៃ។ អ្នកដទៃជាសត្រូវរបស់សេចក្តីសុខ វាជាមិត្តរបស់សេចក្តីច្រណែនទោះបីបងប្អូន មិត្តភក្តិ ប្រពន្ធកូនក៏ដោយ ក៏ខ្វះចិត្តបរិសុទ្ធ សច្ចៈដែរ។ ជាបឋមត្រូវខំរៀនសង្កេតសិក្សាអោយ ជ្រៅជ្រះ រួចត្រូវប្រគល់ភក្តីភាពទៅអោយចិត្តរបស់ខ្លួនឯងល្មមគ្រប់គ្រាន់ ហើយទើបយកភក្តី ឬការទុកចិត្តទៅពិសោធន៍ និងជនដែលអ្នកស្រលាញ់។ ការពិសោធន៍មាន៧ដង បើឃើញថាវាបរិសុទ្ធចំពោះខ្លួនឯងហើយសូមប្រគល់សេចក្តីទុកចិត្ត និង ចិត្តភក្តីពាក់កណ្តាលឱ្យវាចុះ!

យើងឃើញថាមនសិកាភ្ញាក់រលឹករបស់ ខុង ជឺ គឺស្អប់ខ្ពើមមនុស្ស។ គាត់តែងពន្យល់ដល់សិស្សគណជារឿយៗថា "ត្រូវទុកចិត្តអ្នកដទៃជាសត្រូវ តែត្រូវប្រព្រឹត្តតែសេចក្តីល្អទៅជននោះជាដរាប"។

## ឃ. ការយល់ដឹងអំពីវាសនា

ខុង ជឺ ពោលថា " មានមនុស្សរាប់ពាន់អ្នកដើរពីក្រោយខ្ញុំ ហើយសិក្សាទស្សនៈវិជ្ជារបស់ខ្ញុំ ព្រោះគេយល់ថាទស្សនៈវិជ្ជានេះមានផ្លែឈើទិព្វ ដែលគេហៅថា មិញនោះបើ ឈ្ងុះក្តី ចាញ់ក្តី នៅទីបញ្ចប់ក៏គេម្នាក់ៗបានបរិភោគហើយនូវ ផ្លែឈើមិញនេះ"។

សូមបញ្ជាក់ថា ពាក្យមិញរបស់ ខុង ជឺ សម័យនោះមានន័យថា " ឆន្ទៈនៃព្រះជាម្ចាស់" ព្រេងវាសនារបស់មនុស្ស ឬកំលាំងនៃសេចក្តីព្យាយាមដែលមានគោលដៅជាក់លាក់។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

ខុង ជឺ បានពោលទៀតថា " បុគ្គលណាពុំស្គាល់មិញពុំអាចសិក្សាទស្សនះវិជ្ជាខ្ញុំបានឡើយហើយ គ្មានអនាគតដឹកនាំគេបានទេ" ។ ព្រោះទស្សនៈវិទូតែងកំចាត់បង់នូវការសង្ស័យទាំងពួង ។ បណ្ឌិតតែងទាត់ចោលនូវកង្វល់ទាំងឡាយ ។ ឯអ្នកក្លាហានតែងជំរុះនូវការភ័យខ្លាចអោយអស់ពីក្នុងខ្លួន ។

ខុង ជឺ បន្ថែមទៀតថា " គ្រូស្រលាញ់អ្នកស្មើរគ្នាទាំងអស់ ហើយ ចង់អោយអ្នកចេះមុខវិជ្ជាដែលគ្រូមានទាំងប៉ុន្មានដោយគ្មានលាក់លៀមតែគ្រូយល់ថា ខួរក្បាលដែលធម្មជាតិឧប្បត្តិកតាំងពីកំណើតមកវាមានសភាវៈម្យ៉ាងដែលជាអំណោយរបស់ព្រះជាម្ចាស់ តែត្រូវអាចដុះខាត់នូវស្នឹមដែលរំព័ទ្ធអវិជ្ជាបានខ្លះ ។ ខួរក្បាលគ្រូមិនមែនជាខួរក្បាលអាទិទេពទេ តែកាលអាយុ១៥ឆ្នាំ គ្រូស្រលាញ់ជិតដិតនឹងការសិក្សាអាយុ ៣០ឆ្នាំ គ្រូអាចធើបឈរបានហើយស្គាល់ពិភពលោកបានច្បាស់ ។ អាយុ ៤០ឆ្នាំ គ្រូលែងសង្ស័យពីជីវិត ។ អាយុ៥០ ឆ្នាំគ្រូបានស្គាល់នូវក្រិត្យរបស់ព្រះជាម្ចាស់ និងឆន្ទៈរបស់ព្រះអង្គ ។ អាយុ៦០ឆ្នាំគ្រូបាន គោរពព្រះរាជក្រិត្យនេះ ។ លុះអាយុ៧០ឆ្នាំ គ្រូបានឃើញហើយដើរតាមមាគ៌ានៃគំនិតគ្រូដោយពុំហ៊ានមានះបំពារបំពានលើបណ្តូលរបស់ ព្រះជាម្ចាស់ឡើយ ។

ខុង ជឺ បានពោលថា "ប្រសិនបើគោលការណ៏របស់ខ្ញុំជ្រាតជ្រាបគ្រប់ទីកន្លែងក្នុងពិភពលោកគឺ **មិញ** ។ ប្រសិនបើគោលការណ៏ទាំងឡាយនោះធ្លាក់ដល់ដី វាក៏នៅតែជាមិញ ។ គាត់បានខិតខំអស់ពីសមត្ថភាព ដើម្បីការយល់ដឹងពីបញ្ហាមិញ ។ មិញតែងតែប្រែថា ព្រេងវាសនា សំណាង ឬក្រិត្យច្បាប់ហើយដែលខុង ជឺ ផ្តោតទៅលើក្រិត្យច្បាប់របស់ព្រះ អាទិទេព ឬឆន្ទៈរបស់ព្រះអាទិទេព ឬវាជាការផ្តួចផ្តើមឡើងក្នុងឋានៈជាកំលាំងមួយមានគោលបំណង ។

ដូចនេះដើម្បីស្គាល់មិញ មានន័យថាទទួលស្គាល់ភាពមិនអាចជៀសបាននៃពិភពលោក ដើម្បីអោយវាមានអាត្ថិភាពហើយមិនយកចិត្តទុកដាក់ចំពោះជោគជ័យ ឬមិនជោគជ័យរបស់នរណាម្នាក់នោះទេ ។

## ៣. អំពីសាវ័កខុងជឺ

ក្រោយពីខុងជឺ បានទទួលមរណៈភាពទៅបានបន្សល់ទុកនូវសាវ័ក ឬហៅថា **"ទេព្តាទាំង៦"** របស់មជ្ឈមណ្ឌល "**ជូ**" :

- **ស៊ីង សាន** ជាសាវ័កមហាញាណទី១ តំណាងឱ្យខុងជឺនៅសម័យក្រោយ

- **យេន ហ៊ួយ** ជាសាវ័កមហាញាណទី២ ដែលមានសំឡេងពិរោះមានបញ្ញាលើសគេ ហើយត្រូវបានទទួលនាមជាកវីបណ្ឌិត " អ្នកកវីសេកមាស"

- **សឺ លូ** ជាសាវ័កមហាញាណទី៣ អ្នកសុខចិត្តប្រឆាំង នឹងឪពុកជាមហាសេដ្ឋី ដើម្បីសិស្សខុងជឺ

- **សឺ ម៉ានាវ** ជាសាវ័កមហាញាណទី៤ ជាអ្នកមានកិត្តិនាមជាងគេហើយបានរួចជីវិតពីការប៉ងសំលាប់របស់បងបង្កើដោយសារខុងជឺជួយសង្គ្រោះ

- **គង់ យេឆាង** គឺជាសាវ័កមហាញាណទី៥ ជាអ្នកប្រាជ្ញគម្ពីរលី គាត់ចេះពិធីការសែនព្រេន និងសិល្បៈហើយចេះចាប់ទឹកមុខ ( សម្គាល់ទឹកមុខ)



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

- **សួន ឈិង** គឺជាសាវ័កមហាញាណទី៦ ជាអ្នកទៅសងជីវិត (ត្រូវស្លាប់) តែត្រូវបានខុងជឺជួយរំដោះជាផ្លូវនឹងប្រស្នា ។

## ៤. ទស្សនៈនយោបាយរបស់ខុងជឺ

### ក. គោលការណ៍អប់រំ

គុណសម្បត្តិនៃទស្សនវិជ្ជា ខុងជឺ បានអោយតំលៃទៅលើ **សីលធម៌ មនុស្សធម៌ និងយុត្តិធម៌**។ តាមទស្សនៈខុង នៅក្នុងសង្គមមានមនុស្សពីរប្រភេទដែលតែងតែស្វែងរកប្រយោជន៍ពីរផ្ទុយគ្នា។

**-ទីមួយ**:ជាមនុស្សប្រកបដោយគតិបណ្ឌិតដែលសុខចិត្តលះបង់គុណប្រយោជន៍គ្រប់បែបយ៉ាងដើម្បី ស្វែងរកយុត្តិធម៌និងដើម្បីបណ្តុះ កិត្តិសព្ទរបស់ខ្លួន ។

**-ទីពីរ**: ជាមនុស្សសាមញ្ញ ដែលសុខចិត្តលះបង់យុត្តិធម៌ កិត្តិយសដើម្បីស្វែងរកប្រយោជន៍។

ចំពោះច្បាប់ មនុស្សធម៌ យុត្តិធម៌ និងសីលធម៌ ខុងបានអោយដំបូន្មានដូចតទៅ :

**មនុស្សធម៌** : ខុងបានហាមមិនអោយធ្វើសង្គ្រាមជាដាច់ខាត ទោះស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។ ខុងមើលឃើញថាសង្គ្រាមជាប្រភពអមនុស្សធម៌ ។ លោកមិនពេញចិត្តចំពោះអំពើឃោរឃៅ អមនុស្សធម៌ ដែលពួកមនុស្សធ្វើទៅលើ សត្វ និង ទៅលើមនុស្សគ្នាឯង ដូចករណីកងទ័ពចាប់ឈ្លើយសង្គ្រាមមកកាត់ដៃ កាត់ជើងបោះទៅលើចុងលំពែង ចាប់មនុស្សយកទៅស្រុះទឹកក្តៅដូចស្រុះមាន់ គាបក្បាលពិរុទ្ធជនអោយស្លាប់ដោយទារុណកម្ម -ល- ។ អំពើទាំងនេះសុទ្ធតែជាអំពើអមនុស្សធម៌ ។ គាត់បានពន្យល់ថា" អ្នកទាំងឡាយសួរមនុស្សទាំងអស់ទៅមើល តើគេម្នាក់ៗស្រឡាញ់បាបធម៌ឬទេ? តើចង់ព្រាត់ប្រាស់ប្រពន្ធ កូនជាទីស្រលាញ់របស់គេទេ? ហេតុអ្វីមនុស្សយកខួរក្បាលបណ្ឌិតក្នុងជម្រៅ ឆន្ទះទៅផ្សំនឹង "គម្ពីលី"(វៀហាសាស្ត្រ)ហើយបង្គាប់មនុស្សឱ្យរងទុក្ខវេទនាក្នុងភ្នក់ភ្លើងសង្សឹក។

វាពិតណាស់របង និងអង្គប់ត្រូវធ្វើឡើងដើម្បីចាប់ខ្លា។ ប៉ុន្តែ ហេតុអ្វីក៏យកសត្វជាសត្រូវ។ ហេតុអ្វីបានជាអ្នកស្អប់វា ហើយយកវាទៅធ្វើទារុណកម្មដោយខ្វះច្បាប់មនុស្សធម៌? ឱពិភពលោកអ្នកបង្រៀន និងប្រៀនប្រដៅកូនបែបនេះ ម្យ៉ាងទៀតនណាបង្កើតមកឱ្យមានចិត្តឃោឃៅម្លេះ? បើអ្នកជួយគេពុំបានទេ អ្នកគួរតែគេចវេសឱ្យបាត់ទៅដើម្បីកុំឱ្យយល់នូវទិដ្ឋភាពអមនុស្សធម៌នេះឱ្យសោះ។

**យុត្តិធម៌** : ខុងបានមើលឃើញយុត្តិធម៌ក្នុងរូបភាពពីរយ៉ាងគឺ យុត្តិធម៌នៅក្នុងសង្គម និងយុត្តិធម៌ក្នុងគ្រួសារ។ ដំបូងឡើយយុត្តិធម៌កើតមាននៅក្នុងគ្រួសារជាមុនសិន ក្រោយមកទើបវារីករាលដាលដល់សង្គម។ ខុងមើលឃើញយុត្តិធម៌ពួនសំងំនៅក្នុងចិត្ត និងកាយវិការរបស់មនុស្ស ។ ហេតុនេះដើម្បីអោយយុត្តិធម៌ សង្គមកើតមានឡើង ជំហ៊ានទីមួយត្រូវធ្វើអោយមានយុត្តិធម៌នៅក្នុងគ្រួសារជាមុនសិន ។ ខុងបានឈរលើទស្សនៈថា " កូនត្រូវស្តាប់បង្គាប់ឪពុកម្តាយ និង រៀមច្បងរបស់ខ្លួន" ។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

***សីលធម៌*** : ខុង បានបង្គាប់អោយមានមនុស្សគ្រប់វណ្ណៈទាំងអស់នៅក្នុងគ្រួសារ ត្រូវហ៊ានទទួលនូវកំហុសរបស់ខ្លួននៅចំពោះមុខគ្រួសារ និងចំពោះមុខច្បាប់ផងដែរ ។ អ្នកប្រព្រឹត្តល្មើសនិងច្បាប់ ត្រូវទទួលទារុណកម្មអោយសមនឹងកំហុសដែលគេបានសាង ។ ប្រសិនបើកំហុសធ្ងន់ដល់ប្រហារជីវិត អ្នកទោសត្រូវហ៊ានធ្វើអត្តឃាតខ្លួនឯង ។ សីលធមិរបស់ខុង សង្កត់ធ្ងន់ទៅលើទស្សនៈថា មនុស្សម្នាក់ៗត្រូវមានស្មារតីអៀនខ្មាស់ត្រូវចេះយល់នៅអ្វីដែលត្រឹមត្រូវយុត្តិធមិសំរាប់ជីវិត ។ ខុងបានបង្កើតសីលធមិម្យ៉ាងហៅថា " **ជិន** " ប្រែថាស្រឡាញ់អ្នកដទៃ គាត់មានបំណងអោយយើងស្រឡាញ់ផលប្រយោជន៍ និងជីវិតអ្នកដទៃ អោយដូចជារបស់ ខ្លួនផងដែរគឺថា :

-ធ្វើគុណទៅហើយ បើគេតបមកវិញ ចាត់ទុកដូចជាពុំបានធ្វើគុណ ។

-ធ្វើគុណទៅហើយ បើបានផលអាក្រក់វិញ ត្រូវទទួលការពិសោធន៍ដោយដៃពីរ ។

-អំពើណាដែលអ្នកពុំចង់អោយគេធ្វើមកលើរូបអ្នក ចូរអ្នកកុំធ្វើអំពើនោះទៅលើអ្នកដទៃ ។

-អំពើណាដែលអ្នកស្រឡាញ់ចង់បានអោយគេធ្វើមកលើរូបអ្នក ចូរអ្នកធ្វើអំពើនោះទៅអ្នកដទៃជាមុន សិន ។

-អំពើណាដែលធ្វើទៅហើយបានទទួលផលដល់ខ្លួនឯង ហើយបានទុក្ខដល់អ្នកដទៃសូមជៀសវាងកុំធ្វើអំពើនោះដាច់ខាត ។

-បើជួយអ្នកដទៃហើយ បែរជាត្រឡប់មកទទួលទុក្ខទោសវិញ ចូររត់គេចអោយផុតពីទុក្ខទោសនោះអោយបានមុនទុក្ខទោសនោះមកដល់ ។

-ត្រូវទុកអោយអ្នកដទៃនិយាយពីគុណប្រយោជន៍របស់អ្នកវិញទើបប្រសើរជាង ។

-អ្វីដែលអ្នកមិនសប្បាយចិត្តចំពោះអ្នកធំធ្វើមកលើរូបអ្នក កុំយកវាទៅអនុវត្តលើមនុស្សក្រោមបង្គាប់អ្នក ។

-អ្វីដែលអ្នកតូចធ្វើឱ្យអ្នកមិនសប្បាយចិត្ត ចូរកុំយកទៅអនុវត្តចំពោះអ្នកធំ ។

-បើមនុស្សដើរក្រោយវាធ្វើឱ្យអ្នកខឹង ចូរអ្នកកុំយកអំពើរបស់វាទៅធ្វើចំពោះមនុស្សដែលដើរខាងមុខអ្នក ។ បើមនុស្សដើរស្តាំអ្នកធ្វើឱ្យអ្នកខឹង ចូរកុំយកអំពើរបស់វាទៅធ្វើចំពោះមនុស្សណាដែលដើរខាងឆ្វេងអ្នកឱ្យសោះ ។ បើចង់ឱ្យកូនអ្នកគោរពអ្នក អ្នកត្រូវគោរពឪពុកអ្នកជាមុនសិន ។

-បើធ្វើគុណប្រយោជន៍ហើយសូមកុំរំលឹកគុណទាំងនោះនៅចំពោះមុខគេអោយសោះ បើមិនដូចនោះទេគុណប៉ុនភ្នំនឹងត្រូវរលាយ ។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

## ខ. អបរិឧទ្យានៃទស្សនៈវិជ្ជាខុង ជឺ

លោកតែងពោលថា សប្បុរសជនច្រើនណាស់ដែលស្រលាញ់យុត្តិធមិ ស្រលាញ់សុចរិត តែចុះដល់អំពើអាក្រក់កើតឡើងកាន់តែច្រើនហើយ អំពើអកុសលនេះចេះតែរីកដុះដាលមានវឌ្ឍនភាពថែមទៀតនោះ មនុស្សប្រកាន់យកអំពើនេះមកអនុវត្តន៏ដើម្បីក្រពះដើម្បីរុងរឿងដូចគេឯដែរ។ ប៉ុន្តែសប្បុរសជនដែលមានចិត្តបរិសុទ្ធ តែងអង្គុយនៅស្ងៀមសុខចិត្តដាច់ពោះស្លាប់ ព្រោះជននេះមានភ្នែកមិនស្រវាំងដូចមនុស្សសាមញ្ញធម្មតា។ គាត់ដើរពេញពិភពលោកមើលឃើញអំពើអយុត្តិធមិ អំពើទុច្ចរិត រីកចំរើនលើញើសឈាមជនអភ័ព្វ ដែលព្រហ្មលិខិតតម្រូវឱ្យមកកើតជាបាវបំរើសង្គម។ ពិភពលោកមាន ខួរក្បាលអត់បដិវត្តស្បែក និងឆ្អឹងរហូតដល់ថ្ងៃចូលដេកក្នុងម៉ុងវិញ។ លោកគឺជា ទស្សនៈវិទូដែលស្វែងរកភាពត្រឹមត្រូវជាខ្លាំង ពីព្រោះសប្បុរសជនឃើញអយុត្តិធមិជ្រុះអារ៉ាត់អារាយនៅតាមមាត់ទ្វារ ពិភពលោក។ លោកក៏ដាច់ចិត្តដើរចេញពីសង្គមអកុសលនោះទៅរស់នៅក្នុងធម្មជាតិលើកំពូលភ្នំ ស្តាប់សម្លេងថ្ងូចថ្ងូរស្តាប់សត្វវាស្រែកច្រៀងកំសាន្ត ស្តាប់ដង្ហើម និងចង្វាក់បេះដូងដែលដើរក្នុងខ្លួន។ លោកបាននិយាយថា " បើចង់ឱ្យអយុត្តិធមិ ឬទុច្ចរិតបាត់បង់ពីលើលោកនេះទៅ មានតែចាប់ជនអកុសលនោះទៅកប់ទាំងរស់បញ្ចូនទៅក្នុងម៉ុង ដែលដូនតាប្រចាំត្រកូលធ្លាប់ធ្វើមកម្យ៉ាងតែប៉ុណ្ណោះ"។ លោកបន្ថែមថា " ទឹកចិត្តមេត្តា ករុណា មានសេចក្តីស្នេហាលើអ្នកដទៃ" មនុស្សដែលស្រឡាញ់អ្នកដទៃពិត គឺគេមានលទ្ធភាពអនុវត្តន៏ ភារកិច្ចរបស់គេនៅក្នុងសង្គម។ យើងឃើញថាទ្រឹស្តីចិត្តករុណា ប្រាប់ឱ្យកែអយុត្តិធមិ និងទុច្ចរិតដោយលិទ្ធិផ្តាច់ការពីព្រោះ គេពត់ដែកថែបបានដោយងាយតែគេពត់មនុស្សបានដោយពិបាក។ ខុង ជឺ បានសង្កត់ធ្ងន់ទៅលើទឹកចិត្តមេត្តាករុណា និងភាពត្រឹមត្រូវ មានន័យថា" គួរតែនៃ" ស្ថានការណ៏មួយ។ មនុស្សម្នាក់នៅក្នុងសង្គមតែងមានបញ្ហាមួយចំនួន ដែលគេគួរធ្វើដើម្បីផលប្រយោជន៏ផ្ទាល់ខ្លួន ពីព្រោះគេធ្វើប្រកបដោយភាពត្រឹមត្រូវ។ ខ្លឹមសារផ្លូវការនៃភារកិច្ចរបស់មនុស្សនៅក្នុងសង្គមគឺ " ការគួរតែ" របស់ខ្លួនពីព្រោះភារៈកិច្ចទាំងអស់នេះគឺធ្វើជាអ្វីដែលគាត់គួរធ្វើ។ ប៉ុន្តែខ្លឹមសារសំខាន់នៃភារៈកិច្ចនេះគឺ " សេចក្តីស្នេហាអ្នកដទៃ" ពោលគឺ មេត្តាករុណា។

## គ. អត្ថន័យនៃទស្សនៈវិជ្ជារបស់ខុងជឺ

គោលបំណងរបស់ខុងបានផ្តោតទៅលើដំណើរវឌ្ឍនភាព និង ការកសាងសង្គមមនុស្ស។ គោលបំណងនេះបានផ្សព្វផ្សាយមនោគមន៏វិជ្ជារបស់លោក ដោយបណ្តុះបណ្តាលមនុស្សទាំងឡាយអោយចេះដកខ្លួនចេញពីជំនឿអកុសលផ្សេងៗ ហើយមនុស្សចេះស្រឡាញ់ជីវភាពរស់នៅក្នុងសង្គម និងអោយចេះស្វែងរកគ្រប់មធ្យោបាយសំរាប់ទប់ទល់នឹងវិបត្តិផ្សេងៗដែលមនុស្សទូទៅតែងតែជួបប្រទះគ្រប់ៗគ្នាក្នុងដំណើរជីវិតរបស់ខ្លួន។

-ខុងបានទាញសតិសម្បជញ្ញៈរបស់មនុស្សកុំអោយធ្លាក់ចូលទៅក្នុងជំនឿអកុសល។

-ខុងបានបង្ហាត់មនុស្សអោយចេះពឹងផ្អែកលើកំលាំងខ្លួនឯង ហើយអោយចេះជឿលើឆន្ទៈខ្លួនឯងពិសេសគឺត្រូវចេះយកការពិចារណា ធ្វើជាមធ្យោបាយសំរាប់ដោះស្រាយនូវរាល់បញ្ហាដែលកើតមានឡើង។

-ទស្សនៈខុងបានឆ្លុះបញ្ចាំងអោយឃើញច្បាស់ថា គាត់គិតគួរតែការកសាងជីវិតមនុស្សក្នុងលោកិយ៏ និង



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

សណ្តាប់ធ្នាប់បែបសីលធមិសង្គមតែប៉ុណ្ណោះ ។ តែបានណែនាំមនុស្សអោយស្គាល់ទៅបរលោកឡើយ ។

-នៅក្នុងទស្សនវិជ្ជារបស់ខុងក៏មានប្រែពាក្យ "ព្រះជាម្ចាស់" ដែរ ។ តែព្រះអង្គនៅទីនេះមិនមានន័យស្មើនឹងព្រះអាទិទេពនៅក្នុងជំនឿសាសនាណាមួយឡើយ ។ អាទិទេពរបស់ខុងគឺសំដៅលើគំនិតប្រាជ្ញ ហើយនិងក្រមសីលធមិរបស់គាត់តែប៉ុណ្ណោះ ។

-ទស្សនៈនយោបាយរបស់ខុង គឺជាការបញ្ចេញញាណអោយស្វែងរកគ្រប់មធ្យោបាយ ដើម្បីសំរាលទុក្ខលំបាកទាំងឡាយរបស់មនុស្សអោយចេញផុតពីជីវិត ក៏ប៉ុន្តែមិនមែនជាការគិតពីសេចក្តីសុខ និង បុណ្យបាបទៅក្នុងជាតិក្រោយឡើយ ។

### ឃ. គោលការណ៍គុណធម៌របស់ខុងជឺ

គុណធមិរបស់ខុងជឺ សំដៅលើទឹកចិត្តមេត្តា-ករុណា និងភាពត្រឹមត្រូវ ។ លោកថាមនុស្សម្នាក់ៗនៅក្នុងសង្គមសុទ្ធតែមានកិច្ចការដែលគួរធ្វើដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ ប្រកបដោយសីលធមិ និងភាពត្រឹមត្រូវ ។ សកម្មភាពបែបនេះខុងជឺហៅថា " មានគុណធមិ " ប៉ុន្តែប្រសិនបើគេធ្វើកិច្ចការទាំងឡាយដោយគ្រាន់តែពិចារណាតែខ្វះសីលធមិ នោះសកម្មភាពរបស់ពួកគេនឹងក្លាយទៅជាសកម្មភាពមិនត្រឹមត្រូវ និងខ្វះគុណធមិ ។

ម្យ៉ាងទៀត លោកខុង បានចាត់ទុកថាការគ្រប់គ្រងដោយគុណធមិមាន លក្ខណៈប្រសើរជាងការគ្រប់គ្រងដោយច្បាប់ ។ គាត់សន្និដ្ឋានថាការគ្រប់គ្រងបែបនេះអាចមានដំណើរការទៅរួច និងឈានទៅសំរេចបានផ្លែផ្កាទៀតផង ។ ការគ្រប់គ្រងល្អ គឺមានន័យថា ធ្វើអោយសង្គមមានសណ្តាប់ធ្នាប់ និង ជីវភាពជាតិរុងរឿង ។ ចង់គ្រប់គ្រងជីវភាពគ្រួសារអោយបានល្អ លុះត្រាតែចេះកំណត់ទឹកចិត្តត្រឹមត្រូវរបស់ខ្លួនជាមុនសិន ។ អាចកំណត់ទឹកចិត្តត្រឹមត្រូវបាន លុះត្រាតែមានឆន្ទៈស្មោះត្រង់ និងមានការអប់រំ ។ ផ្ទុយទៅវិញនៅពេលដែលមនុស្សមានការអប់រំ នាំអោយជីវភាពគ្រួសាររបស់គេ ត្រូវបានគ្រប់គ្រង ។ បើជីវភាពគ្រួសារត្រូវបានគ្រប់គ្រង នាំអោយជីវភាពជាតិមានសណ្តាប់ធ្នាប់ ។ ពេលនោះពិភពលោកនឹងមានសន្តិភាព ។

### ង. ទស្សនៈនយោបាយគ្រប់គ្រងរដ្ឋ និងជំបូន្មានរបស់ខុងជឺ

ខុងជឺយល់ថាគ្រប់មនុស្សទាំងអស់គួរតែទទួលបាននូវអ្វីដែលគេចង់បាន ហើយអ្វីដែលមនុស្សចង់បានជាងគេនោះ គឺសុភមង្គល ។ ដើម្បីទទួលបានសុភមង្គលមនុស្សហ៊ានពលីគ្រប់បែបយ៉ាង ។ ចេញពីទស្សនៈបែបខុងជឺនេះខុងជឺបានធ្វើការអះអាងទៅលើមុខងាររបស់រដ្ឋាភិបាលថា " រដ្ឋាភិបាលដែលល្អ គឺជារដ្ឋាភិបាលដែលធ្វើយ៉ាងណាឱ្យប្រជាជនរបស់ខ្លួនមានសុភមង្គល ។ ដើម្បីឱ្យសង្គមមានសុភមង្គលខុងបានមើលទំរង់គ្រប់គ្រងរដ្ឋ ក្នុងរូបភាពជាគ្រួសារដ៏សែនធំមួយដែលមានស្តេចជាឪពុក" ។

រដ្ឋប្រភេទនេះមានអត្ថិភាពឡើងគឺ ដើម្បីធ្វើយ៉ាងណាឱ្យជីវភាពនៅក្នុងសង្គមទាំងមូលមានលក្ខណៈប្រសើរជាង គឺដើម្បីបំរើផលប្រយោជន៍គ្រួសារដ៏សែនធំធេងនេះ ។ តាមខុង ជឺ ស្តេចត្រូវតែផ្គត់ផ្គង់ចិញ្ចឹម ថែរក្សា និង



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

បង្ហាត់បង្រៀនដល់ប្រជារាស្ត្រដែលត្រូវជាកូនចៅរបស់ព្រះអង្គ ។ អំណាចនៃរដ្ឋប្រភេទនេះត្រូវតែជាអំណាចបិតុនិយមដែលជាអំណាចរបស់ព្រះមហាក្សត្រ។

ខុងជឺ មិនបានអំពាវនាវឱ្យសមាជិកសង្គមឈានឆ្ពោះទៅរកសមភាពសង្គមឡើយ ។ ខុងចាត់ទុកថានៅក្នុងសង្គមដាច់ខាតត្រូវមានពួកមនុស្សប្រភេទៈ

-ពួកមនុស្សអភិជន

-ពួកមនុស្សសាមញ្ញ

-និងពួកមនុស្សល្ងង់ខ្លៅ។

គ្មាននិន្នាការប្រជាធិបតេយ្យអ្វីឡើយនៅក្នុងទស្សនៈខុងជឺ ។

គាត់យល់ថាក្នុងសង្គមមានមនុស្ស**បីប្រភេទ**គឺ :

-រៀនទើបចេះ

-រៀនមិនចេះ

-និងមិនរៀនតែចេះ។

ខុងជឺបានរិះគន់យ៉ាងខ្លាំងចំពោះពួកមនុស្សសាមញ្ញ ដែលពុំព្រមទទួលស្គាល់ពីទីតាំង និងតួនាទីរបស់ខ្លួនក្នុងសង្គមពីធម្មជាតិ។

ខុងជឺយល់ថា ដើម្បីឱ្យសង្គមមានសណ្តាប់ធ្នាប់ លុះត្រាតែនៅក្នុងសង្គមនោះមានការប្រតិបត្តិបានត្រឹមត្រូវនូវអ្វី ដែលគាត់ហៅថា "ការកែតំរូវឱ្យត្រឹមត្រូវតាមឈ្មោះ" នោះជាមុនសិន។ នោះគឺបានន័យថាម្នាក់ៗត្រូវតែស្គាល់ឈ្មោះ និង មុខងារតួនាទីរបស់ខ្លួនឱ្យបានច្បាស់។ ខ្លឹមសារសំខាន់នៅទីនេះ គឺស្ថិតនៅ ត្រង់ថាអ្នកគ្រប់គ្រងគឺអ្នកគ្រប់គ្រង រដ្ឋមន្ត្រីគឺ រដ្ឋមន្ត្រី ឪពុកគឺឪពុក កូនគឺកូន-ល- ។ គ្រប់ឈ្មោះទាំងអស់សុទ្ធតែមានឋានៈ និងមុខងារខុសៗគ្នា។ បើឈ្មោះណាមួយបំពេញមុខងាររបស់ខ្លួន មិនបានត្រឹមត្រូវ អ្នកតំណាងឱ្យឈ្មោះនោះមិនអាចទៅជាបុគ្គលដ៏ល្អឡើយ ។ ឧទាហរណ៍បើអ្នក ដឹកនាំគ្រប់គ្រងគេមិនខ្វាយខ្វល់ចំពោះវិជ្ជាគ្រប់គ្រងទេនោះ ទោះបីជាអ្នកនោះមានប្រជាប្រិយភាពប៉ុណ្ណាក៏ដោយ ក៏បុគ្គល នោះមិនអាចទៅជាអ្នកដឹកនាំដ៏ល្អបានដែរ។

## ៦. ខុងជឺ និង ទំនៀមទម្លាប់ចិន

នៅក្នុងទំនៀមទម្លាប់កាន់ទុក្ខ ដែលកុលបុត្រកុលធិតាចិនត្រូវធ្វើក្រោយដែលឪពុកម្តាយអនិច្ចកម្មទៅនោះ ខុងជឺបានពោលថា :

" បើមាតាបិតាស្លាប់ កូនទាំងឡាយត្រូវកាន់ទុក្ខ៣ឆ្នាំ ព្រោះថាការសម្តែងកតញ្ញូតាធម៌របស់បុត្រធិតាចំពោះមាតាបិតាត្រូវឱ្យស្របទៅនឹងសេចក្តីលំបាកវេទនានៃអ្នកមានគុណចំពោះកូន ។"



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

" ទារកទាំងឡាយ បើកាលណាមានអាយុពុំទាន់បានបីឆ្នាំ ក្មេងត្រូវនៅក្នុងការបីបមរបស់មាតាបិតាជានិច្ច ការសម្តែងកតញ្ញូតាធមិចំពោះមាតាបិតារបស់ខ្លួន ដោយវិធីយ៉ាងនេះកុលបុត្រកុលធិតាចិនត្រូវធ្វើដោយខាន មិនបាន ។ "

ទស្សនវិជ្ជាខុងជឺបានបង្កប់នូវតំលៃនៃការអប់រំយ៉ាងច្រើន ។ ចំពោះគុណសម្បត្តិនៃទស្សនវិជ្ជា ខុង ជឺ បាន ឱ្យតំលៃទៅលើ **សប្បុរសធមិ មនុស្សធមិ និង យុត្តិធមិ** ។

បណ្ឌិតខុងជឺពោលថា :

" បើគេពុំបង្ខិតបង្ខំមនុស្ស ឱ្យធ្វើយុត្តិធមិទេនោះ នៅក្នុងលោកនេះគ្មាននរណាម្នាក់ស្រឡាញ់យុត្តិធមិទេ តែការបង្ខិតបង្ខំមនុស្សឱ្យធ្វើយុត្តិធមិ ត្រូវអនុវត្តតាមក្រពះដែលតែងបង្ខំមនុស្សឱ្យបរិភោគអាហារ ហើយមិនត្រូវ បង្ខិតបង្ខំ ដោយធ្វើទារុណកម្មឡើយ ។ "

ខុងជឺបានពោលបន្ថែមទៀតថា :

" កូនត្រូវតែស្តាប់បង្គាប់ឪពុកម្តាយ និង រៀមច្បងរបស់ខ្លួន ឱ្យដូចជាកូនបក្សីដែលស្តាប់បង្គាប់មេរបស់វា យ៉ាងដូច្នោះដែរ ។ លក្ខណៈសម្បត្តិរបស់កូន គឺកូនត្រូវគោរពម្តាយហើយស្តាប់បង្គាប់ឪពុកម្តាយ ដូចជាប្អូនត្រូវស្តាប់ បង្គាប់រៀមច្បង ។ នេះពុំគ្រាន់តែយកមកអនុវត្តសម្រាប់ក្រុមគ្រួសាររបស់ខ្លួនប៉ុណ្ណោះទេ ទោះបីអ្នកដ៏ទៃសីល ធមិនេះ ក៏ត្រូវយកទៅអនុវត្តដោយខានពុំបាន ។ "

ឧទាហរណ៍ សិស្សត្រូវតែគោរពហើយស្តាប់បង្គាប់តាមគ្រូរបស់ខ្លួនជានិច្ច ហើយសិស្សណាដែលបាន ចូលទៅ សិក្សាក្រោយគេត្រូវគោរពសិស្សទាំងអស់ដែលបានចូលទៅសិក្សាមិនខ្លួនជាជវាប ទោះបីខ្លួនជាកូនក្នុងត្រកូល ខ្ពស់ជាង គេយ៉ាងណាក្តី ។

ដោយហេតុថាចរិយាវិទ្យារបស់ខុងជឺ ចែងយ៉ាងនេះហើយ បានជានៅក្នុងរឿងព្រេងនានារបស់ចិន គេច្រើន ប្រទះឃើញពាក្យថា "សិស្សច្បង សិស្សប្អូន" យ៉ាងនេះជាដើម ។

ចរិយាសាស្ត្រនៃទស្សនវិជ្ជាខុងជឺ បង្គាប់ឱ្យសិស្សប្អូនស្តាប់បង្គាប់ហើយធ្វើតាមសិស្សច្បងរបស់ខ្លួនជានិច្ច ។ក៏ប៉ុន្តែ សិស្សច្បងត្រូវមានជាពិសេសនូវគុណសម្បត្តិយីគឺយុត្តិធមិជាមុនសិន។

### ៧.ទស្សនវិជ្ជាខុងជឺរំលាយមហាកំពែងចិន

មួយសតវត្សកន្លងមក នៅក្នុងអាចិកំបាំង និង ភាពងងឹតនៃសករាជ ពង្សាវតា និង ឯកសារនានាពុំបានចែង ពីដំណើរទស្សនវិជ្ជាចិនសោះ ។ មកដល់ឆ្នាំ ៣០៧ មុនគ.ស ទើបមានព្រឹត្តការណ៍មួយកើតឡើងជាថ្មី ។ នៅភូមិភាគព្យួសាននៃប្រទេសចិនទាំងមូល ការជ្រួលច្របល់មួយ បានចាប់ផ្តើមឡើងសារជាថ្មី ។ ប្រជារាស្ត្រជាយដែន គេចោលផ្ទះសម្បែង វត់ចោលស្រូវអង្ករ ទ្រព្យសម្បត្តិ និង ហ្វូងសត្វពាហនៈ គេដឹកជញ្ជូនតែរបស់មានតម្លៃបន្តិច បន្តួចសំដៅមកភូមិភាគកណ្តាលដែលជាទីតាំងនៃរាជធានី ។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

រដ្ឋដែលត្រូវរងគ្រោះ ដោយសារវិនាសកម្មមុនគេគឺរដ្ឋ **យេន** និង **ចៅ** ព្រោះពួកអានារ្យ ប្រជាគមបានចាប់ផ្ដើមធ្វើការប្រហារនៅតំបន់ព្រៃកជីក ដែលកប់អនុស្សាវរីយ៍ដ៏ខ្លោចផ្សា ហើយធ្វើឱ្យយើងបំភ្លេចមិនបានរហូតមកដល់សព្វថ្ងៃនេះ ។

នៅទីនោះហើយដែលទស្សនវិទូ **យេ ឆាង** បានបូជាជីវិតដើម្បីគម្ពីរលិរបស់ខុង ជឺ ។

ដោយយល់ថាពួកម៉ុងហ្គោលប្រុងវាយយកអាណាចក្រខ្លួនមុនគេ ព្រះមហាក្សត្រចៅ និង យេន ក៏រកមធ្យោបាយទប់ទល់យ៉ាងសកម្ម ។ ព្រះអង្គទ្រង់បញ្ជាឱ្យប្រមូលវិស្វករនិយន្ដការីទាំងឡាយក្នុងស្រុកមកពិភាក្សាគ្នា ។ ពេលនោះក្នុងចំណោមយោបល់របស់អ្នកប្រាជ្ញទាំងអស់ ព្រះរាជាចិនទ្រង់សព្វព្រះរាជហឫទ័យ ដល់គំនិតអ្នកប្រាជ្ញម្នាក់ឈ្មោះ **ស៊ីវ គង់** ។ អ្នកប្រាជ្ញនេះបានយករូបគំនូរដែលខ្លួនគូរមកបង្ហាញព្រះមហាក្សត្រ ព្រមទាំងចង្អុលនូវប្រយោជន៍របស់រូបនោះផង ។ ស្ដេចយេន និង ចៅយល់ស្របតាមអ្នកប្រាជ្ញគង់ ស៊ីវ ព្រមទាំងបញ្ជាឱ្យគេបើកការដ្ឋាននោះជាបន្ទាន់ ។ រូបគំនូរនោះជារូប "មហាកំពែង" ប្រកបដោយប៉មមីរដេរដាស់ ។

មហាកំពែងនេះក៏ចាប់ផ្ដើមសាងឡើង នៅខាងជើងតំបន់អ័រ-ដុស និង វាលទំនាបនៃស្រុកម៉ង់ ស៊ូ ។ ដើម្បីឱ្យទាន់ពេលវេលាគេត្រូវប្រើមនុស្សរាប់សែននាក់ ។ ហេតុនេះកំណែនត្រូវចាប់ផ្ដើមឡើង ទៅលើប្រជាពលករ ហើយការបង្ហូរឈាមក៏បានកើតឡើងជាមួយគ្នាដែរ ព្រោះជាវិធានការរបស់ស្ដេចយេន ចាប់ប្រារព្ធធ្វើឡើងដោយប្រើកម្លាំង ។

យេន និង ចៅ បានកសាងមហាកំពែងក្នុងឆ្នាំ ៣០៧ មុនគ.ស. មានចម្ងាយបីគីឡូម៉ែត្រ និង ប៉ម៦០០ ។ កំពែងយេនកើតឡើងជាមួយអំណាចផ្ដាច់ការ កើតឡើងពីឈាមប្រជារាស្ត្រចិនរាប់សែននាក់ ហើយជាអនុស្សាវរីយ៍ដ៏ខ្លោចផ្សា សម្រាប់មនុស្សលោកកត់ត្រាក្នុងប្រវត្តិសាស្ត្រ និង មានក្លិនអាសោចរហូតមកដល់សករាជថ្មី ។ ពេលនោះចង្កៀងប្រវត្តិសាស្ត្រចិនក៏បានរលត់ទៅម្ដងទៀត ។

មួយសតវត្សរ៍កន្លងមកទៀត ឆ្នាំ ២៧០ មុនគ.ស. ព្រឹត្តិការណ៍ ដ៏សាហាវមួយបានចាប់ផ្ដើមឡើងជាថ្មី ។ ម្ដងនេះពុំគ្រាន់តែពង្សាវតាចិនប៉ុណ្ណោះទេដែលចារិកនៅក្នុងទំព័ររបស់ខ្លួន សូម្បីតែពង្សាវតាពិភពលោកក៏បានកត់ត្រាគំរង់អាសោចនៃសកម្មភាពនេះដែរ ។

តំណាលថាកាលនោះ **អាណាចក្រស៊ីន** បានចេញមុខធ្វើសង្គ្រាម និង ចិនគ្នាឯងគឺវាងកុលសម្ព័ន្ធអស់រយៈកាលដប់ឆ្នាំទើបអាណាចក្រស៊ីនយកជ័យជំនះលើរដ្ឋចិនទាំងឡាយបាន។

ព្រះមហាក្សត្រស៊ីនក្រោយ ដែលយកជ័យជំនះលើរដ្ឋទាំងឡាយដូចបំណងហើយ ក៏បង្រួបបង្រួមប្រទេសចិនឱ្យមូលត្រកូលគ្នាតែមួយ ហើយស្ដេចស៊ីន ព្រះនាម **ស៊ីន ឆេ ហ្វាង ទី** ក៏បានប្រកាសខ្លួនជាព្រះចៅអធិរាជ ។

ស៊ីន ឆេ ហ្វាង ទី លុះបានឡើងជាព្រះចៅអធិរាជក៏បានចាប់ផ្ដើមដឹកនាំប្រទេសដោយលទ្ធិមួយដែលយកច្បាប់អាជ្ញាសឹកជាធំ ។ ខាងផ្នែកជំនឿ និង ទ្រឹស្ដី ហ្វាំងទីបានបញ្ជាឱ្យលទ្ធិតៅនិយមផ្សំថ្នាំសម្រាប់ជីវិតអមតៈ ។ ស្ដេចអង្គនេះបានបញ្ជាឱ្យគេប្រមូលឯកសារ ក្បួនតម្រាសាស្ត្រ ទស្សនវិជ្ជា របស់ឡៅ ស៊ឺ ព្រមទាំងខុង ជឺ មកទុកក្នុង



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

បណ្ណាល័យ ព្រោះទ្រង់ចង់បំបិតពុំឱ្យប្រជាជនដុះគំនិតអ្វីមួយផ្សេងដទៃពីច្បាប់សឹក ។ តែទោះជាយ៉ាងណាក៏ដោយ ក៏គេឃើញគម្ពីរសាសនា និង ទស្សនវិជ្ជា ជាពិសេសគម្ពីររបស់ខុង ជឺ ត្រូវបានបញ្ញាវន្តមួយក្រុមរក្សាទុកព្រមទាំងនាំគ្នាលបលួចសិក្សាដោយអាថិកំបាំងបំផុត ។

មានរឿងច្រើនណាស់ ដែលអ្នកនិពន្ធចិនសម័យថ្មីនាំគ្នាចងក្រងសម្រាប់ជាឧបករណ៍ បញ្ជាក់ពីព្រឹត្តិការណ៍ប្លែកៗក្នុងរជ្ជកាល "មហាកំពែង" ដូចជា :

តំណាលកាលនោះ មានគ្រួសារពីររស់នៅជិតគ្នា ។ ពួកគេសុទ្ធសឹងតែជាពពួកអ្នកភៀសខ្លួនដែលរត់មកពីតំបន់ឆ្ងាយៗ ហើយបានមកតាំងទីលំនៅលើដីទំនាប ។ គ្រួសារទីមួយមានឪពុក និង កូនស្រីម្នាក់ឈ្មោះនាង **ស៊ី ហួរ** ដែលជានារីប្រកបដោយរូបសម្បត្តិស្រស់សោភា សម្លេងពិរោះដូចសារិកា ហើយមានបេះដូងប្រកបដោយគុណធម៌ ។ គ្រួសារទីពីរគឺគ្រួសារកម្លោះ **ជូ យ័ន** ដែលមានតែម្តាយ ឯឪពុកស្លាប់ក្នុងសមរភូមិទៅហើយ ។ ស៊ី ហួរ និង ជូ យ័ន បានស្រលាញ់គ្នា ដែលជាស្នេហាអមតៈគ្មានកម្លាំងអ្វីអាចបំបែកបំបាក់បានឡើយ ។

ឆ្នាំ២៧០ មុនគ.ស. ព្រះចៅអធិរាជហ្វាំង ទីដែលពិភពលោកចាត់ទុកថាជាមនុស្សផ្តាច់ការទី១ បានវីវក់នឹងអំណាច ។ ក្រៅពីប្រព្រឹត្តកាមគុណជាមួយស្រីស្នំរាប់ពាន់នាក់ ទ្រង់បានប្រមូលរាស្ត្ររាប់សែនគ្រួសារ ឱ្យសង់រាជវាំងនឹងតំណាក់ដ៏ច្រើនលើសលប់ ។ កាលប្បវត្តិចិនតំណាលថាហ្វាំង ទី ចង់ជិះសំពៅលេងកំសាន្ត ទ្រង់ក៏បានបញ្ជាឱ្យរាស្ត្រនាំគ្នាជីកព្រែក នៅមុខព្រះលាននៃតំណាក់របស់ទ្រង់ ។ ការដ្ឋានព្រែកជីកសាងឡើងសាងឡើងតំណាលនឹងការកសាងមហាសំពៅមួយដែលមានមនុស្សរាប់ម៉ឺននាក់ ធ្វើការទាំងថ្ងៃទាំងយប់ ។ ដោយសារតែរាស្ត្រចេះតែរត់គេចវះពុំព្រមធ្វើការស្តេចបានបញ្ជាឱ្យ គេសម្លាប់ចោលអស់ជាច្រើនពាន់នាក់ ហើយបញ្ជាឱ្យដាក់ច្រវាក់ជើងកម្មករថ្មីៗទាំងអស់ ។ មានមនុស្សរាប់ពាន់នាក់ស្លាប់ដោយទឹកស៊ីជើង ព្រោះគេនាំគ្នាឈរធ្វើការក្នុងទឹកទាំងយប់ទាំងថ្ងៃ ។

លុះព្រែកជីករួចហើយហ្វាំងទី បានប្រើកំលាំងមនុស្សឱ្យអូសសំពៅរបស់ខ្លួន ។ យុគរបស់ហ្វាំង ទី ជាយុគងងឹតសូន្យសុង គេគ្មានឃើញពន្លឺសីលធម៌ និង មនុស្សធម៌ឡើយ ។ គេឮសូរតែសម្រែកនៃសេចក្តីទុក្ខវេទនារបស់ប្រជាពលករដែលខំដង្ហោយក្នុងលំហរអាកាសហាក់ដូចជានៅកណ្តាលសាគរគ្មានកោះត្រើយ ។

លុះដល់ឆ្នាំ២៥០មុនគ.ស. ហ្វាំង ទីបញ្ជាឱ្យបើកការដ្ឋានមួយថ្មីទៀតគឺការកសាង "មហាកំពែង" បន្តភ្ជាប់ពីអាណាខេត្រនៃសន្តតិវង្សយេនរហូតមកដល់សមុទ្រ ។

មហាសំណង់នេះសាងឡើងដោយទឹកភ្នែក និង ឈាមរបស់រាស្ត្រចិនព្រោះព្រះហ្វាំង ទី បានប្រើកំលាំងដើម្បីបង្ខំរាស្ត្រឱ្យកសាងរនាំងថ្មនេះ ។ អយុត្តិធម៌ និង អំពើអមនុស្សធម៌ហួសកំរិតបានបង្កើតប្រតិកម្មប្លែកៗ គឺអ្នកស្រុកនាំគ្នាបះបោរទល់នឹងស្តេចវិញ ហើយបង្កើតបានបក្សអ្នកក្លាហានជាច្រើនក្រុមនៅគ្រប់ទីកន្លែង ។ សកម្មភាពចេះតែបង្កើនឥទ្ធិពលខ្លាំងឡើងៗ រហូតបណ្តាលឱ្យរលោះទ័ពស្តេចហ្វាំង ទីអស់ជាច្រើនពាន់នាក់ ។ ពេលនោះព្រះចៅអធិរាជកំណាច បានបញ្ជាឱ្យចាប់បញ្ញាវន្តទាំងអស់មកឃុំឃាំងព្រោះយល់ថា បើខ្វះក្បាលអ្នកចេះដឹង វិបត្តិនេះក៏ពុំអាចកើតឡើងដែរ ។ ក្នុងចំណោមបញ្ញាវន្តទាំងនោះសិស្សគណៈរបស់គម្ពីរ ខុងជឺ ត្រូវបានស្តេចបង្គាប់ឱ្យគេយកទៅសម្លាប់ចោល ដោយច្រានទម្លាក់ទៅក្នុងរណ្តៅមហាកំពែង ។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

ក្រលេកមើលមកគ្រួសារទាំងពីរ ពេលស្រុកកំពង់កើតចលាចល អ្នកស្រុកបាននាំគ្នាដឹកជញ្ជូនគ្រឿងឧបភោគបរិភោគ ទៅសម្ងំនៅក្នុងភ្នំដើម្បីជៀសវាងពីកំណែន ។

ជូ យ័ន បានលាសង្សាររបស់ខ្លួនទាំងអាល័យដើម្បីបំពេញ បេសកកម្មដូចគណៈសិស្សទាំងឡាយដែរ គឺគេត្រូវនាំមហាគម្ពីរខុង ជឺពង្រត់ចេញពីស្រុកស៊ីនទៅកាន់អាណាចក្រចូវ។

តាមកាលប្បវត្តិចិនថា ជូ យ័ន និង មិត្រគេដទៃទៀតត្រូវកងទ័ពស្តេចចាប់បាននៅតំបន់ស្រុក ហៀន គូ គឺតំបន់ដែលឡៅ ស៊ឺ ជិះក្របីឆ្លងកាត់ពីលើកមុន ។ ក្រុមនិស្សិតទាំងប៉ុន្មាន ត្រូវអាជ្ញាធរនាំយកទៅការដ្ឋានមហាកំពែងទាំងអស់ ។

តំណាលកាលនោះនាងក្រមុំ ស៊ី ហួ ក្រោយដែលបានដឹងថា គេចាប់សង្សារនាងយកទៅហើយយុវតីនេះក៏លាឪពុកខ្លួន និង ម្តាយជូយ័នដើម្បីទៅស៊ើបសួរដំណឹង ។ ស៊ី ហួរបានចូលបន្លំខ្លួនក្នុងហ្វូងប្រជាពលកររហូតបានជួបស្តេចហ្វាំង ទី ។ ស៊ី ហួរបានរត់ចេញពីហ្វូងមនុស្សតម្រង់ទៅរកស្តេចហ្វាំងទី ដែលកំពុងទស្សនាយ៉ាងជក់ចិត្ត ។ ជួនពេលស្តេចងាកមកឃើញ ក៏ចាប់ចិត្តនឹងសម្ផស្សរបស់នាង ក៏បញ្ជាឱ្យពលទាហានទុកឱកាសឱ្យនាងចូលជិតយ៉ាងស្រួល ។ កាលណោះយុវតីបានចូលទៅសូមសេចក្តីសណ្តោស ពីព្រះរាជាសូមទ្រង់ដោះលែងសង្សារនាង ។ ហ្វាំង ទីចង់ឃើញជូ យ័នក៏បង្គាប់ឱ្យទាហាននាំជូ យ័នចេញមក តែគេបានទូលទ្រង់វិញថា ជូ យ័ន ជាសិស្សគណៈរបស់ គម្ពីរខុងជឺ ត្រូវបានទំលាក់ក្នុងរណ្តៅប៉ែមមហាកំពែងរួចហើយ ។ លុះដឹងថាសង្សារ នាងស្លាប់ទៅហើយ ស៊ី ហួ វង្វេងបាត់ស្មារតីបោះពួយដូចសត្វអកញី តម្រង់មហាកំពែងបោកបំបែកក្បាល នៅលើសិលាស្លាប់នៅពេលនោះទៅ ។ មរណភាពរបស់ស៊ី ហួ បានបង្កើតជាអព្ភូតហេតុចម្លែកក្នុងប្រវត្តិសាស្ត្រចិន ។

វាយោបក់ផាត់ផ្ទាំងពពកខ្មៅទៅ លើវេហាបណ្តាលឱ្យមេឃងងឹត បន្តិចភ្លៀងក៏ចាប់ធ្លាក់មកដូចគេចាក់ទឹកពីក្អម អសនីបន្ទរសូរម្លងស្ទើរកក្រើកព្រះធរណី ពេលនោះរន្ទះបាញ់បំបាក់មហាកំពែងបណ្តាល ឱ្យបាក់សិលា ទាំងផ្ទាំង៧ លោហិតក្រហមឆ្អៅរបស់ស៊ី ហួ ហូរទៅក្នុងរណ្តៅមរណៈកន្លែងដែលអ្នកប្រាជ្ញ បណ្ឌិត ទស្សនវិទូព្រមទាំងសង្សាររបស់នាងត្រូវគេសម្លាប់ក្នុងទីនោះ ។

អាថិកំបាំងនៃមហាកំពែង ជាអនុស្សាវរីយ៍ដ៏ជូរចត់កត់ត្រាក្នុងទំព័រប្រវត្តិសាស្ត្រចិន និង បានកប់ទុកសុទ្ធតែរឿងសោកសៅពុំអាចបំភ្លេចបាន ។

សន្តតិវង្សហ្វាំង ទី រស់នៅពុំបានប៉ុន្មានក៏អន្តរធានទៅ ក្រោយពីគាត់បានបង្គាប់គេឱ្យដុតចោល គម្ពីរទាំងអស់ក្នុងស្រុកចិននៅឆ្នាំ២១៣ ឆ្នាំមុន គ.ស ។ ពេលនោះប្រជារាស្ត្រចិនទាំងមូលនាំគ្នាខ្លាចស្លាប់ ហើយធ្វើបដិវត្តន៍តទល់នឹងស្តេចកំណាចនេះវិញ។

កាលប្បវត្តិចិនបានពោលថា ៖



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

" ពេលដែលកំពុងមានការ ច្របូកច្របល់ក្រពល់ឈាម, និងក្នុងខណៈ ដែលប្រជារាស្ត្រកំពុងនាំគ្នាដុតវាំងស្តេចហ្វាំង ទី, គេឃើញមនុស្សម្នាក់ជិះសេះស លោតផ្លោតរំលងហ្វូងមនុស្សបោះពួយសំដៅដំណាក់ស្តេចហ្វាំង ទី។ ជននេះកាន់លំពែងមាន ផ្លែជារាងកាំបិតពណ៌មាស, ស្ទុះចូលជាន់កស្តេចហ្វាំង ទី ហើយកាត់ក្បាលយួចេញមកក្រៅ។"

ក្រោយពីស្តេចហ្វាំង ទីចូលទីវង្គត់ទៅ ប្រជារាស្ត្រក៏បានលើកយុវជនលីវ បាង ដែលជាកូនរាស្ត្រសុទ្ធសាធឱ្យឡើងសោយរាជ្យតមកគឺក្នុងឆ្នាំ២០២ មុនគ.ស។

គឺលីវ បាងនេះហើយដែលបានសម្លាប់ស្តេចហ្វាំង ទី, អ្នកស្រុកយល់ថាគុណឧបការៈរបស់ជននេះ មានទំហំធំណាស់ហើយដើម្បីតបស្នងគុណឱ្យសមនឹងសេចក្តីក្លាហានរបស់គេត្រូវតែប្រគល់រាជសម្បត្តិ ឱ្យដល់បុរសនេះ។ ក្រោយដែលបានសោយរាជ្យហើយលីវ បាងក៏បានប្រកាសឱ្យគេដើររកគម្ពីខុង ជឺដែលមាននៅសល់ក្នុងស្រុកចិន។

តំណាលថាកាលនោះមានបុរសម្នាក់ឈ្មោះស៊ូ សុនទុង បានរកឃើញគម្ពីខុង ជឺ ក្នុងក្រហែងថ្មភ្នំមួយក្នុងស្រុករៃ។ បុរស សុន ទុង ក៏នាំយកគម្ពីរនោះមកថ្វាយស្តេច ស្តេចសព្វព្រះរាជហឫទ័យប្រគល់មុខដំណែងឱ្យគាត់ ធ្វើជានាម៉ឺនម្នាក់យ៉ាងធំ, ព្រមទាំងបញ្ជាឱ្យគេ ទៅសាងវិហារមួយនៅស្រុកលូ ដើម្បីឧទ្ទិសដល់វិញ្ញាណខន្ធនៃមហាទស្សនៈវិទូខុង ជឺ ថែមទៀតផង។

សម័យដ៏រុងរឿងរបស់ស្តេចលីវ បាងជារជ្ជកាលដែលប្រវត្តិករទាំងឡាយតែងឱ្យឈ្មោះថាសម័យហាន់។ ប្រជារាស្ត្រសប្បាយរីករាយគ្រប់ទីកន្លែង ហើយគេតែងដាក់ឈ្មោះខ្លួនគេថាជាកូនរបស់ស្តេចសន្តតិវង្សហាន់។

ឯចំណែកទស្សនៈវិជ្ជារបស់ខុង ជឺ ពេលនោះត្រូវគេយកមកអនុវត្តក្នុងនគរចិនទាំងមូល។

គេបាននាំគ្នាទាំងហ្វូងៗទៅសែនផ្នូរឱ្យខុង ជឺ, ដោយប្រទេសចិនមានដីធំទូលាយ ពេកស្តេចក៏ចេញបញ្ជាឱ្យគេកសាងព្រះវិហារខុង ជឺគ្រប់ទីកន្លែងក្នុងស្រុកចិន សម្រាប់អ្នកស្រុកគោរពបូជា, ហេតុដូចនេះហើយ បានជាគេឃើយមានក្លោងទ្វាព្រះវិហាររបស់ខុង ជឺ សេសសល់នៅក្រុងប៉េកាំងរហូតដល់សព្វថ្ងៃនេះ។

ទស្សនៈវិជ្ជារបស់ខុង ជឺ ជាទស្សនៈវិជ្ជា តំណាងការរកឃើញសង្គមមនុស្ស, សង្គមគ្រួសារ, មានឧត្តមគតិទូលំទូលាយផ្នែកសីលធម៌ និងចរិយាធម៌ ដែលពិភពលោកកោតសរសើរយ៉ាងក្រៃលែង។ ទស្សនៈវិជ្ជានេះរះបំភ្លឺលោកីយក្នុងសម័យហាន់, ហើយបានដើរទន្ទឹមជាមួយព្រះពុទ្ធសាសនារហូតមកដល់សព្វថ្ងៃនេះ។ ឯចំណែកទស្សនៈវិទូដែលមានគំនិតបែកមែកបែកធាងពីគម្ពីរខុង ជឺ នឹងព្រះពុទ្ធសាសនាថ្វីត្បិតតែហ៊ានចេញមុខប្រឆាំង នឹងគម្ពីរដើមរបស់ខ្លួនក៏ប៉ុន្តែគេសង្កេតឃើញគន្លងមាគ៌ាខ្លះ របស់មហាទស្សនៈវិទូទាំងនោះដូចជាម៉េង ជឺ, ជូ ហ៊ី, ហ្វាង យ៉ាងមិញ ជាដើម សុទ្ធតែមានលក្ខណៈសមាមតិដូចគ្នាព្រោះគេបានចម្លងមកពីទ្រឹស្តីក្នុងគម្ពីររបស់មហាទស្សនៈវិទូខុង ជឺទាំងអស់។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

## ៨. អវសាននៃជីវិត ខុង ជឺ

អស្តង្គតកាលនៅស្រុកលូប្រកបដោយសោភ័ណភាពណាស់ រស្មីនៃព្រះសុរិយា នៅពុំទាន់ផុតរលត់នៅឡើយ អរុណរង្សីជះកំទេចមាសមកលើសន្ទូងដែលកំពុងដុះប្រណាំងគ្នាតាមជើងភ្នំ ។

នៅគេហដ្ឋានចាស់មួយ ដែលគេសង្កេតឃើញមានតុអាសនៈដាំខ្យងដម្កល់នូវឆាយាយ៉ាងធំរបស់ខុង គ្រូទស្សនវិជ្ជា និង អក្សរជាច្រើនតួដែលគេអានថា សាលាបង្រៀនទស្សនវិជ្ជាជូនោះ សិស្សគណៈជាច្រើនបានមកប្រមូលគ្នាព័ទ្ធជុំវិញគ្រែមួយ ។ នៅក្នុងគ្រែនោះ គេឃើញមានមនុស្សម្នាក់អាយុប្រមាណ៨០ឆ្នាំ ដេកស្តូកស្តឹង ថ្ពាល់ខូង សក់ទុកចងជាដុំ ហើយមានទម្លាក់ជាកំប៉ោយគ្របមានលើស្មា ។

ខ្យល់ជំនោរបោកបក់យ៉ាងខ្លាំង ទ្វីបលោកទាំងមូលស្ថិតក្នុងសភាពលង់លក់អស់ហើយ ព្រោះម៉ោង ១១ យប់ ។ គ្រានោះខុងបាននិយាយទាំងត្រដរ ទៅកាន់សាវកទាំងឡាយថា :

" ថ្ងៃនេះ ជាថ្ងៃបញ្ចប់នៃជីវិតរបស់គ្រូហើយ! ស្តាយណាស់ដោយ ស៊ីង សាន (សាវកមហាញាណច្បង) ពុំនៅ... តែទោះជាយ៉ាងនេះក្តី ក៏គ្រូយល់ថា គ្រូបានស្លាប់ទៅបិទភ្នែកជិតហើយ ។ គម្ពីរទាំង៦ក្បួននេះជាតំណាងរូបគ្រូ គ្រូចង់ឱ្យអ្នកកាន់តាមក្រិត្យវិន័យ ដែលចែងនៅក្នុងគម្ពីរនេះឱ្យបានជាក់លាក់ទាំងអស់គ្នា ។ គ្រូពុំសោកស្តាយទេ ចំពោះអំពើអស់ដែលមនុស្សពុំអនុវត្ត តាមគម្ពីររបស់គ្រូ ថ្ងៃក្រោយគេក៏គង់តែនឹងយកមកអនុវត្តជាមិនខាន ។ "

ខុងនិយាយបណ្តើរ យកដៃជូតទឹកភ្នែកបណ្តើរ ដែលហូរហៀរធ្លាក់រហាមជាប់ថ្ពាល់ដ៏ជ្រីវជ្រួញរបស់គាត់ ។ ដំណើរផ្សងព្រេងរបស់ខុងជឺក្នុងការផ្សាយទស្សនវិជ្ជារបស់គាត់ ពុំបានប្រព្រឹត្តទៅដោយជោគជ័យឡើយ ។ ខុងនឹងស្តាយស្រណោះចំពោះសំដីគាត់ដែលបានសច្ចានៅមុខមហាគម្ពីរចាំងថា គាត់នឹងខំធ្វើតាមបណ្តាំរបស់បុព្វបុរសនៃសន្តតិវង្សនេះ តែគាត់ត្រឡប់ជាទទួលជោគជ័យតិចជាងបរាជ័យទៅវិញ ជាពិសេសនៅក្នុងរដ្ឋស៊ីនដែលជាស្រុកមួយ នៅភូមិភាគខាងជើងនៃប្រទេសចិន ជាស្រុកនៃអ្នកធ្វើសង្គ្រាម ស្អប់ខ្ពើមភាពស្លូតបូត និង សប្បុរសធម៌ និយមសេចក្តីអង់អាច និង សង្គ្រាមប្រល័យលោក ។

ខុងនឹកដល់អនុស្សាវរីយ៍ទាំងឡាយ ដែលធ្វើឱ្យគាត់ធុញទ្រាន់ក្នុងជីវិត ។ ចិត្តរបស់គាត់ស្អប់ការកសាងណាស់តែ សំដី និង ទ្រឹស្តីរបស់ខុងមិនពោលតែពីការពុះពារក្នុងជីវិត ។ គាត់មើលឃើញពិភពលោកពេញទៅដោយមនុស្សកំណាចដែលពិបាកនឹងពន្យល់ដឹកនាំបានដោយស្រួល ។

នៅពេលខុងហៀរទឹកភ្នែកសាវកម្នាក់ៗ លុតជង្គង់ឱនមុខចុះពុំហ៊ានបញ្ចេញវិប្បយោគកម្មរបស់ខ្លួនឱ្យគេឃើញទេ ម្នាក់ៗសុខចិត្តខាំមាត់អត់សង្កត់ចិត្ត ព្រោះខុងពុំបានបង្ហាត់ឱ្យសិស្សសម្តែងសេចក្តីសោកស្រណោះនៅចំពោះបុគ្គលដែលជិតស្លាប់ឡើយ ។

ពេលនោះមហាទស្សនវិទូចិន បក់ដៃឱ្យមនុស្សធាត់ម្នាក់ឈ្មោះ **លី** ចូលមកជិតគាត់ ព្រោះក្នុងចំណោមមនុស្សប្រមាណ៩០នាក់ដែលនៅទីនោះ លីបានយំខ្លាំងធ្វើឱ្យបរិយាកាសស្ថិតក្នុងសំណាញ់នៃទុក្ខសោក ហួសប្រមាណ



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

គាត់ពុំចេះអត់ទ្រាំនូវទុក្ខព្រួយដូចសិស្សដទៃទេ ព្រោះតែពុំបានសិក្សាក្បួនចិត្តសាស្ត្រ ឬ គម្ពីរក្បួនខាងទស្សនរបស់ឪពុកគាត់ លីបែកទៅខាងរបរចិញ្ចឹមសត្វ និងជាគ្រូផ្សំថ្នាំផ្សេងៗ ទៅវិញ ។

គ្រាដែល លី ចូលទៅជិត ខុងបាននិយាយថា:

" លី! ឪពុកអាណិតឯងណាស់ ឪពុកគ្មានព្រទ្យសម្បត្តិអ្វីទុកឱ្យកូនទេ... មុខវិជ្ជាទាំងអស់ដែលឪពុកមានក្នុងក្បួនទាំង៦ ចូរកូនទុកឱ្យកូនរបស់ឯង បើប្រសិនជាវាកើតមកប្រុសចូរកូនបង្ហាត់អក្សរវា ឱ្យបានចេះខ្លះ លុះវាធំឡើងល្មមដឹងក្តី ចូរកូនបញ្ជូនវាទៅភូមិឈ្មួនឈាន នៅក្នុងស្រុកវៃ ឱ្យវាទៅរកស៊ីង-សានហើយរៀនសូត្រទស្សនវិជ្ជាពីគេមកកុំខាន នេះជាបណ្តាំដែលឪពុកសូមឱ្យកូនអនុវត្តជាដាច់ខាត ។"

ខុងបានឆ្លៀតឱកាសជាចុងក្រោយដើម្បីដោះស្រាយប្រស្នា និង សំនួរចម្លើយ របស់សាវកដែលចង់សួរគាត់ ។

សាវកម្នាក់សួរខុងថា :

" លោកគ្រូ! បើកើត ហើយស្លាប់ទៅវិញ ជួបហើយវិលជាព្រាត់វិញ ហេតុអ្វីក៏ចាំបាច់កើត និង ជួបធ្វើអ្វី?"

ខុងឆ្លើយថា:

" ថ្ងៃរះឡើងហើយរមែងលិចទៅវិញ បើមានថ្ងៃហើយរមែងមានយប់ បើមានយុត្តិធមិហើយរមែងមានភាពកខ្វក់លាមកនៃអំពើអយុត្តិធមិ ។ នេះជាគូររបស់ធម្មជាតិដែលបានកើតមកព្រោះវាជាហេតុមានបច្ច័យ ក្នុងធម្មជាតិព្រោះគេចង់បង្កើតស្រីម្នាក់ ឱ្យនៅជាមួយប្រុសម្នាក់ដើម្បីឱ្យមានកូនមួយ ។ ចូរសិស្សសង្កេតមនុស្សប្រុសឱ្យបានច្បាស់សង្កេតមនុស្សស្រីឱ្យបានច្បាស់ បន្ទាប់មកត្រូវសង្កេតកូនរបស់អ្នកទាំងពីរ នេះឱ្យច្បាស់ផង ។"

បន្ទាប់មកខុងចាប់សូត្របទកំណាព្យ សូត្រចប់ក៏ឈប់ស្ងៀមហើយបិតភ្នែកជិត ខ្លួនស្តូកស្តឹងដូចគល់ឈើ ។ សាវ៉កស្មានថាខុងលាចាកលោកទៅហើយ ក៏នាំគ្នាយំ តែលុះខុងដកដង្ហើមតាមចង្វាក់ធម្មតាវិញ គេក៏ស្រាប់តែនាំគ្នាបញ្ឈប់សំណោក នៅពេលនោះដែរ ។

លោកហ្វុង យូ ឡាន់ បានប្រាប់យើងថា កាលខុងភ្លឹកមួយភ្លែតទៅនោះ សាវកទាំងអស់មានសេចក្តីត្រេកអរគ្រប់គ្នា គេបាននាំគ្នា យកសម្លៀកបំពាក់ក្របាមពណ៌មាសដែលលោកម្ចាស់លូបានទិញទុកឱ្យ ជាច្រើនថ្ងៃមកហើយនោះមកពាក់គ្រប់គ្នា ។

ខ្លះស្លៀកពាក់ជានាយទាហាន ខ្លះជាសេនាបតី ខ្លះជាស្តេច ខ្លះជាចៅក្រម និង អភិជន ។

លោកហ្វុង យូ ឡាន់ បានពន្យល់ថា កាលខុងជិតធ្វើមរណៈកាលទៅ គាត់មានកង្វល់យ៉ាងខ្លាំង ពឆ្នាំដែលខុងត្រលប់មកពីការធ្វើដំណើរផ្សងព្រេង គាត់បាននិពន្ធគម្ពីរ១ឈ្មោះ **និទីយរដូវ** និង **សរទរដូវ** ។ ក្រោយមកគាត់បានសរសេរកំណាព្យ ស្តីពីវិប្បយោគកម្មជាច្រើនសៀវភៅ តែសព្វថ្ងៃពុំដឹងជាទៅទីណា ។ តែមកដល់គ.ស. ទី៣ និង ទី៤ គេបានប្រទះនូវបទកំណាព្យដ៏ពិរោះ មានន័យរបស់មហាកវីចិនធំៗជាច្រើន



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

ដែលមានមតិខ្លះយល់ថា ប្រហែលជាមានត្រកូលណាមួយបានរក្សាកំណាព្យរបស់ខុងទុកមករហូតសម័យនោះ ក៏ពុំដឹង ។

ពួកសាវ័ករបស់ខុងបាននាំគ្នា ស្លៀកសំលៀកបំពាក់ប្លែកយ៉ាងនេះ ព្រោះគេចង់ធ្វើឱ្យខុងសប្បាយចិត្តនៅពេលមុនស្លាប់ ពោលគឺគេចង់បំភ័ន្តភ្នែកខុងឱ្យជឿថា ទស្សនវិជ្ជាខុងត្រូវអ្នកនគរគ្រប់កុលសម្ព័ន្ធ មានសេនាបតី នាម៉ឺន រាស្ត្រ មន្ត្រីទទួលយកទៅអនុវត្តគ្រប់គ្នារួចហើយ ។

ចំពោះបណ្ឌិត លី វ៉ូ ជី បានពោលថា ពួកគេធ្វើយ៉ាងនេះព្រោះខុងអាក់អន់ចិត្តចំពោះសិស្សគណដែលជាសេនាបតី មន្ត្រីក្នុងវាំងពុំបានមកជួបជុំគ្នានៅពេលគាត់លាផែនដីនេះទៅ ។

ចំណែកលោកស្មេ គ្រីល បានជឿថា ព្រោះខុងធ្លាប់មានមុខងារជាសេនាបតីម្នាក់នៅរាជវង្សលូ ។ នៅពេលមុនគាត់ធ្វើមរណកាលទៅ គេត្រូវយកសំលៀកបំពាក់ទាំងអស់នោះមកស្លៀកពាក់ឱ្យគាត់ឃើញដើម្បីឱ្យមហាទស្សនវិទូសប្បាយចិត្តផង និង ដើម្បីសមនឹងឋានៈចាស់របស់គាត់ផង ។

កណ្តាលសន្ធិយាស្ងាត់សូន្យសុងគឺម៉ោង១២យប់ក្រោយដែលផ្តែផ្តាំនូវពាក្យពេចន៏ដ៏មានខ្លឹមសារ ព្រមទាំងប្រគល់ទាំង៦ឱ្យកូនរួចមក ខុងជឺមហាទស្សនវិទូចិនដ៏កំពូល បានលាចាកលោកទៅ ដោយបានស្រាយចំណងលោកិយ៍ឱ្យប្រជាពលករចិនរាប់សែននាក់ ។ មុនពេលដាច់ខ្យល់ ខុងលើកដៃចង្អុលអក្សរជូ ដែលជាបណ្តាំជាគ្រាអវសានរបស់គាត់ចំពោះសិស្ស ហើយជាសញ្ញានៃបេសកកម្មមួយដែលសិស្សគ្រប់គ្នាត្រូវការពាររក្សា និង ផ្សាយទៅគ្រប់ទិសទីកុំបីឱ្យចន្លោះឡើយ ។

ខុង ស្លាប់ចោលពិភពលោកដ៏ស្អុយកខ្វក់ ដែលជាគំរង់អាសោចនៃជីវិតរបស់គាត់ ។

តាំងពីថ្ងៃដែលខុងកើតមក ខុងពុំដែលស្គាល់ថាអ្វីហៅថាសប្បាយឡើយ ។ ជីវិតរបស់ខុងជាគុកច្រវាក់អន្ទាក់ខ្នោះឃ្នាង តែខុងខំត្រដរឱបក្រសោប យកមកដាក់លើដើមទ្រូងខុងឱបទុក្ខនៃជីវិតដោយហត្ថាទាំងគូ ហើយច្របាច់រួតរិតកំទេចទុក្ខព្រួយនោះដោយទស្សនវិជ្ជា ។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

# សេចក្តីសន្និដ្ឋាន

ខុងជឺជាមហាទស្សនះវិទូប្រទេសចិនតំណាងការវិវត្តន៍ និងការកសាងសង្គមមនុស្ស។ ខុងជឺបានផ្សាយមនោគមន៍វិជ្ជាបណ្តុះបណ្តាលចិត្តមនុស្សឱ្យងាករេពីជំនឿអកុសលផ្សេងៗហើយនាំឱ្យប្រជាជន មានជំនឿជឿនលឿនទៅលើកំលាំរបស់ខ្លួនឯងឱ្យចេះស្រលាញ់ជីវិតស្រលាញ់ជីវភាពរស់នៅក្នុងសង្គម ថែមទាំងជួយរកគ្រប់មធ្យោបាយ មកតទល់ប្រឆាំង នឹង វិបត្តិផ្សេងៗដែលគ្រប់មនុស្សតែងតែជួបប្រទះគ្រប់គ្នាក្នុងដំណើរជីវិតរបស់ពួកគេ។ មិនត្រឹមតែប៉ុណ្ណោះ ខុង ជឺ បានបង្រៀន ឱ្យមនុស្សគ្រប់រូបមានសីលធម៌នៅក្នុងខ្លួន ស្រលាញ់យុត្តិធម៌ ស្អប់សង្គ្រាម និងអំពើហឹង្សាការបណ្តុះគំនិតបែបនេះពិតជាបានផ្តល់នូវប្រយោជន៍ឱ្យ មនុស្សជាតិទាំងមូលព្រោះថាបើមនុស្សម្នាក់ៗ មានគំនិតបៀតបៀន ឈ្នានីស ច្រណែន រំលោភ បំពានគ្នាទៅវិញទៅមកឥតឈប់ឈរនោះពួកគេប្រាកដជារស់នៅក្នុងភាពភ័យខ្លាចជាពិសេសប្រជារាស្ត្រដែលរស់នៅក្នុងប្រទេសដែលមានអ្នកដឹកនាំប្រកាន់នូវជំហរបែបនេះតែម្តង។ ហើយបើគេប្រកាន់ជំហរបែបនេះនោះអ្វីក៏គេពុំអាចទទួលបានដែរ បើយើងនិយាយទៅលើប្រទេសមួយវិញនោះប្រទេសនោះពិតជាពុំមានការអភិវឌ្ឍន៍ឡើយ ហើយគ្រប់វិស័យនៅក្នុងប្រទេសគេក៏ពុំអាចមានដំណើការទៅមុខបានដោយរលូន ព្រមទាំងបាត់បង់ នូវធនធាន មនុស្សមែទៀតផង។ យើងដឹង ហើយថាធនធានមនុស្ស គឺជាកត្តាមួយដ៏សំខាន់ និងចំបងក្នុងការអភិវឌ្ឍន៍ ប្រទេសជាតិ។ ទស្សនះរបស់ខុងជឺមួយដែរនោះ គឺខុងជឺបានឱ្យមនុស្សគ្រប់រូបទទួលស្គាល់នូវ ឋានះ ទីតាំង មុខងារ និងតួនាទីរបស់ខ្លួនបើនណាម្នាក់បំពេញមុខងាររបស់ខ្លួនមិនបានត្រឹមត្រូវទេនោះខុងជឺបានចាត់ទុកថា បុគ្គលនោះមិនអាចទៅជាបុគ្គលដ៏ល្អឡើយ។ ចំនុចនេះគឺចង់ផ្តោតសំខាន់ ទៅលើសមិទ្ធិផលដែលគេបានបង្កើត បើយើងឱ្យមនុស្សម្នាក់ដែលពុំមានសមត្ថភាពក្នុងការធ្វើការងារមួយទៅធ្វើវាសួរថា តើគេអាចធ្វើបានដែរ ឬទេ? យើងចាត់ទុកថាគេធ្វើបានទៅចុះ តែយើងនឹងប្រាកដជាដឹងច្បាស់ថាការងានោះមិនល្អឡើយ ហេតុនេះទើបខុងជឺ បានឱ្យមនុស្សត្រូវតែស្គាល់ពីទីតាំង ក៏ដូចជាតួនាទីរបស់ខ្លួន ដើម្បីទទួលបាននូវលទ្ធផលមួយដែលល្អគួរ ជាទីគាប់ចិត្ត។

សរុបសេចក្តីមកទស្សនះវិជ្ជានយោបាយរបស់ខុង ជឺ ពិតជាបានរួមវិភាគទានយ៉ាងសំបើមក្នុងការរុញច្រានឱ្យទ្រឹស្តី នយោបាយបែបទស្សនះវិជ្ជាសីលធម៌មានអត្ថិភាពឡើង។ អ្វីដែលសំខាន់នៅក្នុងទស្សនះរបស់លោកគឺ ខុង ជឺបានប្រើកំលាំងក្រៅមកជួយរៀបចំ និងដោះស្រាយបញ្ហាក្នុងសង្គមមនុស្សឡើយ។ តែលោកបានប្រើក្បួនច្បាប់សីលធម៌ធ្វើជាមូលដ្ឋាន សំរាប់ដោះស្រាយបញ្ហាសង្គមទៅវិញ។



This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com

# ឯកសារយោង

☽☽☽☽★☾☾☾☾


១. សៀវភៅវិទ្យាសាស្ត្រនយោបាយ រៀបរៀងដោយ សុខ គាង

២. សៀវភៅគួរយល់ដឹងទស្សនវិជ្ជា រៀបរៀងដោយ ខ្លួត ធីតា

៣. សៀវភៅមូលដ្ឋានគ្រឹះទស្សនវិជ្ជា រៀបរៀងដោយ ខ្លួត ធីតា

៤. សៀវភៅទស្សនវិជ្ជាខុង ជឺរំលាយមហាកំពែងចិនភាគ១ រៀបរៀងដោយ សុខ សុត្ថាល

៥. សៀវភៅទស្សនវិជ្ជាខុង ជឺរំលាយមហាកំពែងចិនភាគ២ រៀបរៀងដោយ សុខ សុត្ថាល

៦. សៀវភៅប្រវត្តិទស្សនៈ សាសនា សីលធម៌ នយោបាយ រៀបរៀងដោយ ឥន្ទ ឱមសាម៉េង




This PDF was created using the Sonic PDF Creator.
To remove this watermark, please license this product at www.investintech.com